សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំ និងការប្រព្រឹត្តទៅរបស់សន្ទាត់ចោមចៅទី២

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **អាន នុតយុត្តះវិ**

សាស្ត្រាចារ្យណែនាំ
លោក **ថោង ចន្ថា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

## សេចក្ដីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទឈ្មោះ **អាន នុតយុត្តៈធិ** និស្សិត (ក្រុម $L_4B_1$) ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៥-២០១៩ ។

**ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

ជីតាឈ្មោះ **ហែម សារឿន** ជីដូនឈ្មោះ **ឃួន ភូរីចន្ថណា** លោកឪពុកឈ្មោះ **យឹម សុខសំអូន** អ្នកម្ដាយឈ្មោះ **ហែម រិទ្ធិភា** និងអ្នកម្ដាយឈ្មោះ **ហែម លក្ខិណា** ជាទីគោរព ដែលមាននូវមហាគុណដ៏ឧត្តុងឧត្តម និងធំធេងបំផុតគ្មានអ្វីមកប្រៀបស្មើរបាននឹងមិនអាចបំភ្លេចបានក្នុងជីវិតកូនចៅ ព្រោះលោកទាំងប្រាំជាអ្នកទំនុកបម្រុងទាំងការរស់នៅ និងការសិក្សារៀនសូត្រ ផ្ដល់ភាពកក់ក្ដៅ តាំងពីកូនចៅនៅតូចៗ រហូតដល់ធំដឹងក្ដី លោកតែងតែអប់រំ ទូន្មានប្រៀនប្រដៅអោយកូនចៅខិតខំតស៊ូព្យាយាមក្នុងការសិក្សា ជៀសឆ្ងាយពីគ្រឿងឧបាយមិនល្អ អោយកូនសេពគប់មនុស្សល្អ និងលត់ដំខ្លួនអោយក្លាយទៅជាមនុស្សល្អនៅក្នុងសង្គម។ ត្បិតតែលោកទាំងប្រាំជាគ្រួសារមានជីវភាពលំបាក ត្រកូលកសិករ ប៉ុន្តែលោកទាំងប្រាំខិតខំប្រឹងប្រែងមិនខ្លាច នឿយហត់រិះរកគ្រប់របរ ធ្វើយ៉ាងណាបញ្ជូនកូនចៅគ្រប់គ្នាអោយបានចូលសាលា និងសិក្សាអោយបានចប់ថ្នាក់ខ្ពស់ ព្រោះលោកមិនចង់ឃើញកូនចៅរបស់លោកជាមនុស្សល្ងង់ខ្លៅ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកការិយាល័យសិក្សា ការិយាល័យស្រាវជ្រាវ ព្រមទាំងបណ្ណារក្សទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយ កម្លាំងចិត្តក្នុងការដឹកនាំ គ្រប់គ្រង ជ្រោមជ្រែង និងបង្ហាត់បង្រៀនដល់ខ្ញុំបាទឲ្យទទួលបាននូវចំណេះដឹងយ៉ាងច្រើនកន្លងមកនេះ។

លោកសាស្ត្រាចារ្យណែនាំ **ថោង ចន្ធា** លោកបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ និងចំណាយពេលវេលាផ្ទាល់ខ្លួនដ៏មានតម្លៃក្នុងការជួយពន្យល់ណែនាំ ផ្ដល់មតិយោបល់ល្អៗ និងផ្ដល់ឯកសារមួយចំនួន ព្រមទាំងជួយកែសម្រួល កែតម្រូវយ៉ាងយកចិត្តទុកដាក់បំផុតរហូតសារណាមួយក្បាលនេះបានបញ្ចប់ និងលេចចេញជារូបរៀងឡើងបានដោយជោគជ័យ។

មិត្តរួមថ្នាក់ឈ្មោះ **ឆី ពិសី** ដែលបានចំណាយពេលវេលាមានតម្លៃខិតខំជួយកែលម្អចំណុចខ្វះខាត សម្រួលឃ្លា និងពិនិត្យអក្ខរាវិរុទ្ធ។

ជាចុងក្រោយខ្ញុំបាទ សូមសម្ដែងនូវសេចក្ដីគោរព និងអំណរគុណយ៉ាងជ្រាលជ្រៅ ជាពិសេសសូមបួងសួងវត្ថុស័ក្តិសិទ្ធិទាំងឡាយជួយតាមថែរក្សាលោកអ្នកមានគុណអោយជួបតែសេចក្ដីសុខ។

# អារម្ភកថា

ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ពិតជាមានសារសំខាន់ណាស់ដើម្បីជាបុព្វហេតុក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសកម្ពុជា ជាពិសេសគឺការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នេះតែម្តង។ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់គឺជាវិធីដ៏ល្អមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការងាយស្រួលគ្រប់គ្រងប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រោះមានតែឃុំសង្កាត់នេះទេដែលស្ថិតនៅជិតពួកគេជាង។ មេឃុំចៅសង្កាត់គឺជាបុគ្គលមួយដ៏សំខាន់សម្រាប់នាំសាររាជរដ្ឋាភិបាល ទៅកាន់ប្រជាពលរដ្ឋមូលដ្ឋាន ក៏ដូចជានាំពាក្យពីប្រជាពលរដ្ឋមូលដ្ឋានទៅកាន់រាជរដ្ឋាភិបាលវិលអំពីផែនការ ការអនុវត្តន៍ ស្ថានភាពផលលំបាក សេវាសាធារណៈ មណ្ឌលសុខភាព និងភាពវិជ្ជមាន ភាពអវិជ្ជក្នុងឃុំ សង្កាត់ ផ្សេងៗ-ល-។ ដោយហេតុទាំងនេះហើយទើបធ្វើអោយរដ្ឋបាលឃុំ សង្កាត់និងប្រជាពលរដ្ឋមាន ភាពប្រាស្រ័យទាក់ទងគ្នាល្អព្រមទាំងមានភាពជិតស្និតនឹងគ្នាផងដែរ និងងាយស្រួលក្នុងការដោះស្រាយបញ្ហាវិវាទជូនពួកគាត់ទាន់ពេលវាលាដែលធ្វើអោយប្រជាពលរដ្ឋមានភាពកក់ក្តៅ និងមានទំនុកចិត្តមកលើរាជរដ្ឋាភិបាលកាន់តែប្រសើរឡើង។

ដោយហេតុដូចបានរៀបរាប់ជូនខាងលើនេះហើយ ទើបធ្វើអោយខ្ញុំបាទសម្រេចចិត្តជ្រើស រើសយកប្រធានបទ "**ការរៀបចំ និងការប្រព្រឹត្តទៅរបស់សង្កាត់ចោមចៅទី២**" យកមកសរសេរជា សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ព្រោះប្រធានបទនេះអាចអោយយើងយល់ដឹងអំពីការអនុវត្តន៍ ការគ្រប់គ្រង ការដោះស្រាយនូវបញ្ហាវិវាទផ្សេងៗ និងយល់ដឹងអំពីតួនាទីនឹងភារកិច្ចរបស់ មន្ត្រីសង្កាត់ចោមចៅទី២ ថាបានគោរពតាមគោលការណ៍ច្បាប់បានកំរិតណាដែរ។ ម្យ៉ាងវិញទៀត ខ្ញុំចង់អោយមិត្តអ្នកអាន យល់ដឹងអោយច្បាស់ថាតើរដ្ឋបាលឃុំ សង្កាត់នេះផ្តោតសំខាន់ទៅលើអ្វី ហេតុអ្វីបានជាយើងត្រូវយល់ដឹងអំពីការគ្រប់គ្រងឃុំសង្កាត់នេះ ហើយថាតើឃុំសង្កាត់នេះមានទំនួលខុសត្រូវយ៉ាងណាខ្លះដែរ។

តាមរយៈការសិក្សាស្រាវជ្រាវក្នុងប្រធានបទសារណានេះ បើទោះបីជាមានការខិតខំប្រឹង ប្រែងស្រាវជ្រាវតាមរយៈឯកសារគោលណ៍នានា ក៏ដូចជាការទទួលបានឯកសារផ្សេងៗពីសំណាក់រដ្ឋបាលសង្កាត់ចោមចៅទី២ យ៉ាងណាក្តីក៏ការសិក្សាស្រាវជ្រាវមួយនេះគង់តែនៅមានការខ្វះខាត ចំណុចមិនពេញលេញណាមួយ និងកំហុសខុសឆ្គងត្រង់កន្លែងណាមួយជាក់ជាពុំខាតឡើយទាំង ផ្នែកខ្លឹមសារ អក្ខរាវិរុទ្ធ និងអត្ថបទជាដើម។

ជាចុងក្រោយយើងខ្ញុំរីករាយព្រមទទួល និងរងចាំនូវការរិះគន់ដើម្បីស្ថាបនាពីគ្រប់មជ្ឈដ្ឋាននានា ពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តនិស្សិត និងមិត្តអ្នកអានគ្រប់រូបដើម្បីកែលម្អអោយកាន់តែប្រសើរ កាន់តែមាន អត្ថន័យ និងកាន់តែមានអត្ថប្រយោជន៍ជាងនេះនៅពេល ក្រោយៗទៀត។

# មាតិកា

សេចក្តីផ្តើម ............................................................................................................១

១.លំនាំបញ្ហានៃការស្រាវជ្រាវ ..........................................................................................១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ .......................................................................................២

៣.គោលបំណងនៃការស្រាវជ្រាវ .........................................................................................២

៤.ដែនកំណត់នៃការស្រាវជ្រាវ ............................................................................................ ៣

៥.វិធីសាស្ត្រស្រាវជ្រាវ ......................................................................................................... ៣

៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............................................................................................ ៣

ជំពូកទី១៖ ការរៀបចំ និងការប្រព្រឹត្តទៅនៃឃុំ សង្កាត់

១.១.ការរៀបចំរដ្ឋបាលឃុំ សង្កាត់.............................................................................................៥

១.១.១.ការបោះឆ្នោះជ្រើសរើសក្រុមប្រឹក្សា.......................................................................៥

១.១.២.សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់..........................................................................៦

១.១.៣.រចនាសម្ព័ន្ធនៃរដ្ឋបាលសង្កាត់ ................................................................................ ៧

១.១.៤.តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលសង្កាត់ .......................................៨

១.២.កិច្ចការរដ្ឋបាលឃុំ សង្កាត់........................................................................................... ១១

១.២.១.លិខិតបទដ្ឋានគតិយុត្តឃុំ សង្កាត់ ......................................................................... ១១

១.២.២.ការគ្រប់គ្រងឯកសារ.................................................................................................១៣

១.២.៣.ការគ្រប់គ្រងបុគ្គលិក................................................................................................១៣

១.២.៤.ការប្រព្រឹត្តទៅនៃកិច្ចការប្រជុំ ................................................................................. ១៤

ជំពូកទី២៖ ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលសង្កាត់ចោមចៅទី២

២.១.ស្ថានភាពភូមិសាស្ត្រ .................................................................................................. ១៥

២.១.១.កសិកម្ម................................................................................................................... ១៦

២.១.២.ស្ថានភាពសង្គមកិច្ច.................................................................................................១៦

២.២.ការគ្រប់គ្រងហិរញ្ញវត្ថុរបស់សង្កាត់ ........................................................................... ១៨

២.២.១.ការរៀបចំ និងការអនុម័តថវិកាសង្កាត់....................................................................១៩

២.២.២.ចំណូល និងចំណាយថវិកា ...................................................................................... ១៩

២.២.៣.ប្រព័ន្ធទូទាត់ គណនេយ្យ និងកិច្ចលទ្ធកម្មឃុំ សង្កាត់ ...............២០

ជំពូកទី៣៖ ផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល
៣.១.ក្របខណ្ឌអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ........ ២២
៣.១.១.ចក្ខុវិស័យអភិវឌ្ឍន៍........ ២២
៣.១.២.គោលដៅអភិវឌ្ឍន៍ ........ ២២
៣.១.៣.យុទ្ធសាស្ត្រអភិវឌ្ឍន៍........ ២៣
៣.២.កម្មវិធីអភិវឌ្ឍន៍........ ២៦
៣.២.១.ក្របខណ្ឌវិនិយោគ........ ២៦
៣.២.២.ក្របខណ្ឌផ្តល់សេវា ........ ២៦
៣.២.៣.ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា ........ ២៧
៣.៣.ការតាមដាន និងការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍........ ២៧
សន្និដ្ឋាន ........ ៣០
អនុសាសន៍
គន្ថនិទ្ទេស
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងរបបដ៏រាំរៃក្នុងសម័យខ្មែរក្រហមឆ្នាំ ១៩៧៥ ដល់ ១៩៧៩ បានធ្វើអោយប្រទេសកម្ពុជាបាត់បង់នូវហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្រ្ត សេវាកម្ម និងរចនាសម្ព័ន្ធរដ្ឋបាលផ្សេងៗ-ល- ស្ទើរតែទាំងស្រុង។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ការគ្រប់គ្រងរដ្ឋបាលចាប់ផ្តើមករកើតឡើងវិញពីចំនុច០ ដោយរាជរដ្ឋាភិបាលកម្ពុជាពីរបបខ្មែរក្រហមដ៏សាហាវយង់ឃ្នង។

ការគ្រប់គ្រងប្រព័ន្ធរដ្ឋបាល គឺជាផ្នែកមួយដ៏សំខាន់បំផុតក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍នៅកម្ពុជា។ ហើយការធ្វើកំណែទម្រង់នយោបាយរដ្ឋបាលរបស់រាជរដ្ឋាភិបាល បានធ្វើអោយកម្ពុជាមានសេដ្ឋកិច្ចរីកចម្រើនជឿនលឿន មានស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់ល្អ។ ម្យ៉ាងវិញទៀត ដើម្បីផ្តល់អោយប្រជាពលរដ្ឋនូវប្រសិទ្ធភាពខ្ពស់ក្នុងការទទួលបាននូវការការពារសន្តិសុខក្នុងមូលដ្ឋាន ការដោះស្រាយជម្លោះផ្សេងៗក្នុងមូលដ្ឋាន សេវាសាធារណៈយ៉ាងឆាប់រហ័ស មានភាពងាយស្រួល និងទាន់ពេលវេលារដ្ឋាភិបាលកម្ពុជាបានដាក់អោយអនុវត្តនូវគោលនយោ បាយវិមជ្ឈការ។ វិមជ្ឈការ គឺជាប្រព័ន្ធគ្រប់គ្រងមួយដែលរដ្ឋបាលថ្នាក់ជាតិធ្វើការផ្ទេរអំណាច និងការទទួលខុសត្រូវមួយចំនួនអោយទៅអាជ្ញាធរមូលដ្ឋានចាត់ចែង បម្រើផលប្រយោជន៍ផ្ទាល់របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាននោះ។ វាបានលើកកម្ពស់ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ លើកកម្ពស់ជីវភាពរស់នៅ និងការផ្តល់ជូននូវឱកាសកាន់តែច្រើនដល់ប្រជាពលរដ្ឋ និងថែមទាំងធានាអោយមានការអភិវឌ្ឍន៍មួយ ប្រកបដោយនិរន្តរភាព ព្រមទាំងការផ្តល់សេវាកម្មនានាជាមូលដ្ឋាន។ យោងទៅតាមការរៀបរាប់បណ្តាលខាងលើនេះ យើងឃើញថារាជរដ្ឋាភិបាលកម្ពុជាគឺកំពុងមានការយកចិត្តទុកដាក់ជាខ្លាំង ក្នុងការគ្រប់គ្រងរដ្ឋបាល ថ្នាក់មូលដ្ឋានអោយកាន់តែប្រសើរឡើង និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ ដោយស្របទៅនិងគោលនយោបាយប្រជាធិបតេយ្យ និងយុត្តិសាស្រ្តចតុកោណជំណាក់កាលទី៤ អាណត្តិទី៦ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសនោះគឺការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នេះតែម្តង។

ក្នុងឆ្នាំ ១៩៨០ សង្កាត់ចោមចៅត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ បន្ទាប់ពីបានប្រកាសរួចហើយ ការងាររដ្ឋបាលត្រូវបានដំណើរការយ៉ាងរលូន។ ដោយសារកំណើនប្រជាជន និងសេដ្ឋកិច្ចមានកំណើនកើនឡើងយ៉ាងឆាប់រហ័ស ពិបាកក្នុងការគ្រប់គ្រងនិងផ្តល់សេវាជូនដល់ប្រជាពលរដ្ឋសង្កាត់ក៏បានធ្វើការស្នើសុំទៅក្រសួងមហាផ្ទៃក្នុងឆ្នាំ ២០១៦ តាមរយៈសាលាខណ្ឌពោធិ៍សែនជ័យ និងសាលារាជធានីភ្នំពេញ។ សង្កាត់ចោមចៅបានស្នើទៅរដ្ឋមន្រ្តីក្រសួងមហាផ្ទៃធ្វើការបំបែកសង្កាត់

ជាពីរបន្ថែមទៀតតាមរយៈ សំណើររបស់សាលាខណ្ឌពោធិ៍សែនជ័យដោយយោងតាមអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៦ ។

ឃុំ សង្កាត់ជានីតិបុគ្គល[1] និងត្រូវបានគេចាត់ទុកថាជាកន្លែងផ្តល់សេវាសាធារណៈយ៉ាងសំខាន់ពីរាជរដ្ឋាភិបាល ជូនដល់ប្រជាពលរដ្ឋមូលដ្ឋាន។ អំណាចដឹកនាំ និងគ្រប់គ្រងឃុំ សង្កាត់បានមកដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយ ស្មើភាព ដោយចំពោះ និងដោយសម្ងាត់ក្នុងក្របខ័ណ្ឌនៃឃុំសង្កាត់នីមួយៗ[2] ដោយធ្វើឡើងពីសំណាក់ប្រជាពលរដ្ឋជាអ្នកធ្វើការសម្រេចចិត្តបោះឆ្នោតដោយផ្ទាល់។ ឃុំ សង្កាត់ត្រូវគ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួនដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ អំណាចបញ្ញត្តិ អំណាចប្រតិបត្តិក្នុងការគ្រប់គ្រងមូលដ្ឋានត្រូវផ្តល់អោយឃុំសង្កាត់ហើយអំណាចនេះ ត្រូវអនុវត្តស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ ។[3]

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនូវប្រធានបទស្តីពី **ការរៀបចំ និងការប្រព្រឹត្តទៅរបស់សង្កាត់ចោមចៅទី ២** បានចោទជាបញ្ហាមួយចំនួនដូចជា ៖

- តើតួនាទី និងភារកិច្ចអ្វីខ្លះដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានក្នុងការបំពេញមុខងាររបស់ខ្លួន អោយបានល្អប្រសើរ? តើការអនុវត្តនូវតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំសង្កាត់ក្នុងមូលដ្ឋាន បានកម្រិតណា?
- តើដំណើរការនៃការគ្រប់គ្រងរដ្ឋបាលសង្កាត់ចោមចៅទី២មានលក្ខណៈបែបណា បើប្រៀបនិងគោលការណ៍នៃច្បាប់?
- តើផែនការនៃការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់សង្កាត់ចោមចៅទី២ជាអ្វី មានមុខងារ និងអត្ថប្រយោជន៍យ៉ាងណាខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺបានផ្តោតលើគោលបំណងសំខាន់ជាច្រើន ដែលក្នុងនោះយើងចង់បញ្ជាក់អោយកាន់តែច្បាស់អំពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ រចនាសម្ព័ន្ធ អំពីតថភាពជាក់ស្តែងក្នុងការដោះស្រាយបញ្ហាប្រឈម និងការផ្តល់សេវាសាធារណៈក្នុងមូលដ្ឋានជូនដល់ប្រជា

[1] មាត្រា ២ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
[2] មាត្រា ៤ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
[3] មាត្រា ៥ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ពលរដ្ឋ។ បន្ថែមពីលើនេះទៅទៀត ការសិក្សាស្រាវជ្រាវនេះ ចង់រួមចំណែកក្នុងការកែលម្អនូវចំណុចខ្វះខាត ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរចនាសម្ព័ន្ធរដ្ឋបាលរបស់ឃុំ សង្កាត់ និងដើម្បីពង្រឹងសមត្ថភាពផ្ទាល់ខ្លួន ព្រមទាំងស្វែងយល់បន្ថែមអំពីៈ

- សមត្ថភាពរបស់មន្ត្រីរាជការក្នុងការអនុវត្តការងារនៅក្នុងមូលដ្ឋានឃុំ សង្កាត់
- បញ្ហាប្រឈម ដំណោះស្រាយ និងលំហូរនៃកិច្ចការភារកិច្ចរបស់ក្រុមប្រឹក្សាសង្កាត់ចោមចៅទី២
- គោលការណ៍នៃការអភិវឌ្ឍន៍ និងផែនការក្នុងការដឹកនាំរបស់ចៅសង្កាត់ចោមចៅទី២

## ៤. ដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានដែនកំណត់ និងវិសាលភាពគ្របដណ្តប់តែនៅលើសកម្មភាពនៃការអនុវត្តការងាររបស់រដ្ឋបាលសង្កាត់ចោមចៅទី២នៅឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨ និងត្រីមាសទី២នៃឆ្នាំ២០១៩ ព្រមទាំងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល។ ដូច្នេះប្រធានបទស្តីពី **ការរៀបចំ និងការប្រព្រឹត្តទៅរបស់សង្កាត់ចោមចៅទី២** នេះយើងខ្ញុំសូមធ្វើការបកស្រាយទៅលើចំណុចមួយចំនួននិងដំណើរការនៃការគ្រប់គ្រងរដ្ឋបាល បញ្ហាប្រឈម ការរៀបចំ ការប្រព្រឹត្តទៅ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់សង្កាត់ចោមចៅទី២។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវទៅលើប្រធានបទស្តីពី **ការរៀបចំ និងការប្រព្រឹត្តទៅរបស់សង្កាត់ចោមចៅទី២** នេះគឺគ្រាន់តែជាសារណាបញ្ចប់ការសិក្សាប៉ុណ្ណោះដូច្នេះយើងខ្ញុំធ្វើការស្រាវជ្រាវ និងដកស្រង់ទៅតាមឯកសារដែលមានស្រាប់ដូចជា

- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា
- សៀវភៅរបាយការណ៍ប្រចាំឆ្នាំ និងប្រចាំខែ
- សៀវភៅផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល និងឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងប្រធានបទ
- និងស្រាវជ្រាវតាមបណ្តាញអ៊ីនធឺណេតជាដើម។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវលើប្រធានបទ «**ការរៀបចំ និងការប្រព្រឹត្តទៅរបស់សង្កាត់ចោមចៅទី២**» ត្រូវបានរៀបចំដូចខាងក្រោមៈ

- សេចក្តីផ្តើម

- ជំពូកទី ១ ៖ គឺបានរៀបរាប់បង្ហាញអំពី ការរៀបចំ និងការប្រព្រឹត្តទៅនៃឃុំ-សង្កាត់ដោយលើកយកនូវរាល់លិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធមកធ្វើការបកស្រាយ។
- ជំពូកទី ២ ៖ គឺបានរៀបរាប់បង្ហាញអំពី ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលសង្កាត់ចោមចៅទី២ ដោយធ្វើការសិក្សាអំពីផែនការ ការគ្រប់គ្រងហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រក្នុងការរៀបចំ ដឹកនាំ គ្រប់គ្រងរដ្ឋបាលរបស់សង្កាត់ចោមចៅទី២។
- ជំពូកទី ៣ ៖ គឺបានរៀបរាប់លើកបង្ហាញអំពី ផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដោយធ្វើការបង្ហាញខ្លឹមសារ និងគោលការណ៍ផ្សេងៗ។
- សេចក្តីសន្និដ្ឋាន
- អនុសាសន៍
- គន្ថនិទ្ទេស
- ឧបសម្ព័ន្ធ

# ជំពូកទី១
# ការរៀបចំ និងការប្រព្រឹត្តទៅនៃឃុំ សង្កាត់

## ១.១ ការរៀបចំរដ្ឋបាលឃុំ សង្កាត់

### ១.១.១ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន តាមការបោះឆ្នោតទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើរភាព ដោយចំពោះ និងដោយសម្ងាត់។ ការបោះឆ្នោតជ្រើសរើសនេះត្រូវធ្វើឡើងរៀងរាល់៥ឆ្នាំម្តង ដោយការបោះឆ្នោតនៅគ្រប់ឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងនៅថ្ងៃអាទិត្យតែមួយថ្ងៃគត់[4]។ ដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺត្រូវតែអនុវត្តទៅតាមប្រព័ន្ធសមាមាត្រដែលបែងចែកអសនៈទៅតាមមធ្យមភាគខ្ពស់បំផុត ក្រោមការរៀបចំចាត់ចែង និងគ្រប់គ្រងរបស់គណៈកម្មការជាតិរៀបចំបោះឆ្នោត។ ដំណើរការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ និងត្រូវចាត់ចែងរៀបចំទៅតាមលំដាប់ដូចតទៅៈ

**ក.ការចុះឈ្មោះជាបេក្ខជនបោះឆ្នោត**

គ្រប់បេក្ខជនដែលមានបំណងចង់ឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតែបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណៈបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវទៅតាមលក្ខខណ្ឌ នៃបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលបានចុះហត្ថលេខាដោយប្រធានគណៈបក្សនយោបាយ ឬតំណាងដែលទទួលបានការផ្ទេរសិទ្ធិទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតយ៉ាងតិចរយៈពេល៩០ថ្ងៃ មុនថ្ងៃបោះឆ្នោតដោយភ្ជាប់មកជាមួយនូវបញ្ជីរាយនាមបេក្ខជន ដែលមានចំនួនយ៉ាងហោចណាស់ស្មើរពីរដង នៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រជាជនទាំងពីរភេទដែលមានបំណងចងឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវតែបំពេញនូវលក្ខខណ្ឌដូចខាងក្រោមៈ

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាន និងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះនៅក្នុងបញ្ជីអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច២៥ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

[4] ច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមឃុំ សង្កាត់,ឆ្នាំ២០១៦,មាត្រា៣ថ្មី។

**ចំពោះបេក្ខជនដែលត្រូវហាមឃាត់មិនអោយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់មានដូចជា៖**

- សមាជិករដ្ឋសភា ព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ សមាជិករដ្ឋាភិបាល និងចៅក្រម
- ប្រតិភូរាជរដ្ឋាភិបាល អភិបាល ឬអភិបាលរាជធានី ក្រុង ស្រុក ខណ្ឌ
- សមាជិកគណៈកម្មការជាតិរៀបចំការបោះឆ្នោត បុគ្គលិកបម្រើការងារនៅគណៈកម្មការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់។
- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងតំណែង
- ព្រះសង្ឃ ឬបុព្វសាសនា
- ស្មៀនឃុំ សង្កាត់

**ខ. ការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត**

គណៈកម្មការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការរៀបចំបញ្ជី ឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អោយបានមុនយ៉ាងតិច៩០ថ្ងៃ មុនថ្ងៃបោះឆ្នោត[5]។ បន្ទាប់ពីរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់រួច គណៈកម្មការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់រយៈពេលនៃការត្រួតពិនិត្យ បញ្ជីឈ្មោះអ្នកបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗមិនត្រូវតិចជាង ១៥ថ្ងៃឡើយ។

ដើម្បីមានសិទ្ធិចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋ ទាំងពីរភេទត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានអាយុ១៨ឆ្នាំឡើងទៅគិតចាប់ពីថ្ងៃបោះឆ្នោត
- មិនស្ថិតក្នុងស្ថានភាពជាទណ្ឌិត និងស្ថានភាពជាជនវិកលចរិកជាដើម[6]។

### ១.១.២ សមាសភាពក្រុមប្រឹក្សា ឃុំ សង្កាត់

ដោយផ្អែកទៅតាមការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់មានដូចតទៅ៖

| | |
|---|---|
| លោក វ៉ា សារ៉ង | ប្រធានក្រុមប្រឹក្សា |
| លោកស្រី យ៉ង់ សំអឿន | សមាជិក |

[5] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់,ឆ្នាំ២០១៦,មាត្រា៤៣

[6] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់,ឆ្នាំ២០១៦,មាត្រា១៩ថ្មី

| | |
|---|---|
| លោក ភួង ផា | សមាជិក |
| លោកស្រី ស៊ុន បញ្ញា | សមាជិក |
| លោក សួស ម៉ានិត | សមាជិក |
| លោក ម៉ាក់ បារាំង | សមាជិក |
| លោកស្រី រឹន ផល្លី | សមាជិក |
| លោកស្រី ស្វាយ ថន | សមាជិក |
| លោកស្រី ឆេង បុប្ផា | សមាជិក |
| លោកស្រី ម៉ាន់ ស្រីរ័ត្ន | សមាជិក |
| លោក ម៉ម ទុំ | សមាជិក |

**១.១.៣ រចនាសម្ព័ន្ធនៃរដ្ឋបាលសង្កាត់**

រដ្ឋបាលឃុំ សង្កាត់ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ហើយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់នោះជាមេឃុំ ចៅសង្កាត់[7]។

រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវមានរចនាសម្ព័ននៃរដ្ឋបាលឃុំ សង្កាត់ជាក់លាក់របស់ខ្លួនដោយផ្អែកតាមបញ្ញត្តិដែលចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

- ក្រុមប្រឹក្សាឃុំ សង្កាត់ មានសមាជិកពី ៥,៧,៩ ឬ១១នាក់ផ្អែកទៅតាមភូមិសាស្ត្រ និងចំនួនប្រជាជនដែលរស់កំពុងតែរស់នៅក្នុងឃុំ សង្កាត់។ ចំនួនជាក់ស្តែងត្រូវកំណត់ដោយអនុក្រឹត្យ។
- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវមានប្រធាន០១រូប ដែលហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាមេឃុំ ឬចៅសង្កាត់។
- មេឃុំ ចៅសង្កាត់អាចមានជំនួយការ០២រូប គឺជំទប់ទី១ ឬចៅសង្កាត់ទី១ និងជំទប់ទី២ ឬចៅសង្កាត់ទី២[8]។
- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឲ្យមានមេភូមិម្នាក់សម្រាប់ភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួនដោយអនុវត្តតាមសេចក្តីណែនាំលេខ ០០៤ស.ណ.ន ចុះថ្ងៃទី១៧ ខែមិនាឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃស្តីពីបែបបទនៃនីតិវិធីជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ចរបៀបរាបរយធ្វើការងារ របស់មេភូមិ។ មេភូមិ គឺជាតំណាងអោយប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែ

[7] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា២៥

[8] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា២៦

រយៈ ចម្បងសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់។ មេភូមិត្រូវមានជំនួយការរបស់ខ្លួន ០២រូបម្នាក់ជាអនុប្រធានភូមិ និងម្នាក់ទៀតជាសមាជិកភូមិ។

- មេឃុំ ចៅសង្កាត់អាចចាត់តាំងបង្កើតគណៈកម្មាធិការនានាបានតាមការចាំបាច់។ គណៈកម្មាធិការនីមួយៗមានសមាជិកយ៉ាងតិច០៣នាក់ ដើម្បីផ្តល់យោបល់ និងជួយការងារដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់អំពីបញ្ហាជាក់លាក់ណាមួយ។ គណៈកម្មាធិការនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់អោយធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួនក្រៅពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អោយធ្វើជាប្រធានក៏បាន[9]។
- ឃុំ សង្កាត់នីមួយៗមានស្មៀនមួយរូបដែលត្រូវបានតែងតាំង និងបម្រើការងារនៅក្នុងក្របខ័ណ្ឌ រដ្ឋបាលក្រសួងមហាផ្ទៃ[10]។ ស្មៀនឃុំ សង្កាត់ទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងការបំពេញមុខងាររបស់ខ្លួន ស្មៀនឃុំ សង្កាត់ត្រូវតែអព្យាក្រឹត្យមិនលម្អៀង ហើយត្រូវប្រកាន់ឥរិយាបថអោយបានស្មើៗគ្នា ចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងឃុំ សង្កាត់ដោយមិនប្រកាន់និន្នាការនយោបាយ។

### ១.១.៤ តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលសង្កាត់

ជាទូទៅរដ្ឋបាលឃុំ សង្កាត់មានតួនាទី និងការទទួលខុសត្រូវដាច់ដោយឡែកពីគ្នាទៅតាមមុខដំណែងរបស់ខ្លួន។

**ក. ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់**

ប្រធានក្រុមប្រឹក្សាឃុំសង្កាត់ មានតួនាទី ជាធិបតីក្នុងសម័យក្រុមប្រឹក្សាឃុំ សង្កាត់នៅពេលមានការប្រជុំ។ មិនតែប៉ុណ្ណោះ ប្រធានក្រុមប្រឹក្សាឃុំសង្កាត់ធានាអោយសម័យប្រជុំក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួនមានដំណើរការបានត្រឹមត្រូវតាមវិធាន និងបទបញ្ជាដែលបានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ និងរក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំរបស់ក្រុមប្រឹក្សាសង្កាត់[11] ។

ជាមួយគ្នានេះផងដែលក្រុមប្រឹក្សាឃុំ សង្កាត់ ក៏អាចធ្វើប្រតិភូកម្មអំណាចដល់ចៅសង្កាត់ផងដែរ[12]។ លើសពីនេះទៅទៀតក្រុមប្រឹក្សាឃុំ សង្កាត់ធានាអោយមានកិច្ចប្រជុំក្រុមប្រឹក្សាយ៉ាងតិច

[9] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា២៧
[10] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា២៨
[11] ច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់ ឆ្នាំ២០០១ មាត្រា១៣
[12] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១,មាត្រា៥២

មួយដងក្នុងមួយខែជាដាច់ខាត។ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ក៏ត្រូវរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ដោយចាត់វិធានការដូចជា ការវាយតម្លៃអាទិភាព និងសកម្មភាពអភិវឌ្ឍន៍ ប្រមូលផ្តុំសេចក្តីត្រូវការ និងកំណត់អាទិភាពនៃសេចក្តីត្រូវការទាំងនោះអោយបានជាក់លាក់ដោយផ្អែកលើធនធានដែលមានស្រាប់ រៀបចំកម្មវិធីអភិវឌ្ឍន៍ទៅក្នុងគម្រោងថវិកាឃុំសង្កាត់ ផ្តល់សេវា និងអភិវឌ្ឍន៍តាមថវិកាដែលឃុំមាន ហើយត្រួតពិនិត្យនិងវាយតម្លៃចំពោះលទ្ធផលក្រោយការអនុវត្តន៍។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ពីការអភិវឌ្ឍន៍ជូនប្រជាពលរដ្ឋរបស់ខ្លួន និងធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំសង្កាត់ និងចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយតម្កល់ទុកជាសាធារណៈ ចម្លងចែកជូនអង្គការ សមាគមន៍ និងសាធារណៈជនសំខាន់គិតត្រឹមថ្លៃដើម[13]។

**ខ. មេឃុំ ឬចៅសង្កាត់**

"ចំពោះមេឃុំ ឬចៅសង្កាត់មានតួនាទីអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ការធ្វើសេចក្តីរាយការណ៍ពីសកម្មភាពរបស់ខ្លួនយ៉ាងតិចមួយខែម្តង។ ហើយក៏នៅមានការអនុវត្តបទបញ្ញត្តិ និងគោលការណ៍នានាដែលទទួលបានពីក្រុមប្រឹក្សាឃុំ សង្កាត់ និងការផ្តល់យោបល់ផ្សេងៗទៀត និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុ និងចាត់ចែងអនុវត្តតួនាទី និងមុខងារ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ព្រមទាំងកិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់បានប្រគល់អោយ"[14]។ ជាងនេះទៅទៀត ចៅសង្កាត់ក៏ជាអ្នកអនុវត្តតាមគោលការណ៍របស់រដ្ឋាភិបាល និងទទួលការធ្វើប្រតិភូកម្មអំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ដែលអ្វីសំខាន់នោះ ចៅសង្កាត់ជាមន្ត្រីអគ្រានុកូលដ្ឋានផងដែរ។

**គ. ជំទប់ឃុំឬ ចៅសង្កាត់**

ជំទប់ឃុំ ឬចៅសង្កាត់រងមានតួនាទីជាជំនួយការរបស់ចៅសង្កាត់[15] ហើយអនុវត្តន៍ភារកិច្ចដែលចៅសង្កាត់ប្រគល់អោយ និងជាជំនួយការចៅសង្កាត់តាមឋានានុក្រមនៃចៅសង្កាត់រងពេលចៅសង្កាត់ឬមេឃុំអវត្តមាន។ ហើយក្នុងនោះផងដែរចៅសង្កាត់រងជាជំនួយការចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ចហិរញ្ញវត្ថុ រីឯចៅសង្កាត់រងទី២ជាជំនួយការចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ចសេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ។

[13] ច្បាប់ស្តីពពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១,មាត្រា ៧០

[14] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១,មាត្រា៣៩

[15] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១.មាត្រា២៩

**ឃ. គណៈកម្មាធិការនានា**

គណៈកម្មាធិការនានារបស់ឃុំ សង្កាត់ ត្រូវបង្កើតឡើងក្នុងករណីដែលឃុំសង្កាត់មានការចាំបាច់ក្នុងការអនុវត្តន៍គោលនយោបាយរបស់ឃុំ ហើយគណៈកម្មាធិការនានាមានតួនាទីផ្តល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ដូចជាការកសាងផែនការថវិការឃុំសង្កាត់ រាយការណ៏អំពីការអភិវឌ្ឍន៍ប្រចាំខែរបស់ខ្លួន និងផ្តល់យោបល់ពីវិធានការដែលត្រូវអនុវត្តពាក់ព័ន្ធជាមួយនឹងការងារ។

**ង.ស្មៀនឃុំ**

នៅគ្រប់ឃុំ សង្កាត់ទាំងអស់ត្រូវមានបុគ្គលិករដ្ឋបាលក្រសួងមហាផ្ទៃ ហើយជាមន្ត្រីសាធារណៈតែងតាំងដោយប្រកាសរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយអាចផ្លាស់ប្តូរតាមការស្នើសុំរបស់មេឃុំ ចៅសង្កាត់ ផ្អែកតាមការសម្រេចពីក្រុមប្រេក្សាឃុំ សង្កាត់ នោះរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងចេញប្រកាសផ្លាស់ប្តូរ។ ហើយស្មៀនឃុំជាមន្ត្រីក្របខណ្ឌរដ្ឋបាលរបស់ក្រសួងមហាផ្ទៃដែលចាត់អោយទៅបម្រើការងារជាជំនួយការរដ្ឋបាលឃុំ សង្កាត់។ ដែលមានភារកិច្ចធានានិរន្តភាពកិច្ចការរដ្ឋបាលឃុំ សង្កាត់។ ដូច្នេះ ស្មៀនឃុំ សង្កាត់មានចៅហ្វាយពីរ គឺមន្ត្រីក្រសួងមហាផ្ទៃ និងក្រុមប្រឹក្សាឃុំសង្កាត់។

**ឆ. មេភូមិ**

មេភូមិមានតួនាទីទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន ហើយជាតំណាងអោយប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាសង្កាត់។ បង្កើតការពិគ្រោះយោបល់ទទួលការណែនាំ និងកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាសង្កាត់របស់ខ្លួន។ មិនតែប៉ុណ្ណោះ មេភូមិមានភារកិច្ចអនុវត្តកិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់អោយដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍសេដ្ឋកិច្ចក្នុងភូមិ ផ្តល់យោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែង និងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន[16]។ ចូលរួមកិច្ចប្រជុំគណៈកម្មាធិការនានារបស់សង្កាត់ ដើម្បីផ្តល់យោបល់អំពីកិច្ចការនៅក្នុងភូមិរបស់ខ្លួនដូចជាផ្តល់យោបល់ដល់គណៈកម្មាធិការភូមិអំពីតម្រូវការ និងផលប្រយោជន៍របស់ភូមិ ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិអំពីរបៀបបង្កើន និងកសាងសមត្ថភាព និងធនធានរបស់ភូមិផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការផែនការ និងថវិកាភូមិអំពី (តម្រូវការ និងអាទិភាពរបស់ភូមិដើម្បីបញ្ចូលក្នុងផែនការអភិវឌ្ឍន៍សង្កាត់ក្នុងភូមិរបស់ខ្លួន ការ

[16] សៀវភៅក្រសួងមហាផ្ទៃ,ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់តាមបែបវិមជ្ឈការ,ឆ្នាំ ២០០៧,ទំព័រ២១

ត្រួតពិនិត្យនិងការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍សង្កាត់ ត្រូវធ្វើសេចក្តីរាយការណ៍រាល់បញ្ហាដែលពាក់ព័ន្ធ និងភូមិរបស់ខ្លួនដើម្បីដាក់បញ្ចូនក្នុងរបាយណ៍ការប្រចាំខែរបស់ក្រុមប្រឹក្សាសង្កាត់)។ ការចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាសង្កាត់ ត្រូវធានាផ្តល់ពត៌មានជាឯកសារសាធារណៈដែលពាក់ព័ន្ធទៅនឹងភូមិជូនប្រជាពលរដ្ឋរបស់ខ្លួនអោយបានដឹង។ ឯកសារទាំងនោះរួមមានពត៌មានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាសង្កាត់ ផែនការអភិវឌ្ឍន៍សង្កាត់ និងថវិកាសង្កាត់ ហើយត្រូវទទួលខុសត្រូវអនុវត្តកិច្ចការដែលបានប្រគល់អោយដោយក្រុមប្រឹក្សាសង្កាត់របស់ខ្លួន។

## ១.២. កិច្ចការរដ្ឋបាលឃុំ សង្កាត់

### ១.២.១. លិខិតបទដ្ឋានគតិយុត្ត ឃុំ សង្កាត់

លិខិតរដ្ឋបាលឃុំ សង្កាត់ គឺជាលិខិតដែលកំណត់នូវវិធាន បទបញ្ញត្តិ បទបញ្ជា ឬគោលការណ៍នានាសម្រាប់ការគ្រប់គ្រង ការតែងតាំង ការបង្កើតនូវយន្តការ និងការណែនាំអនុវត្តកិច្ចការនានា។ លិខិតបទដ្ឋានគតិយុត្តរដ្ឋបាលឃុំ សង្កាត់ មានដូចជា៖

**ក. ដីការឃុំ សង្កាត់**

ដីការឃុំ សង្កាត់គឺជាលិខិតបទដ្ឋានគតិយុត្តដែលកំណត់នូវបញ្ញាត្តិទាំងឡាយដែលរដ្ឋបាលឃុំ សង្កាត់បង្កើតឡើងក្នុងគោលដៅបម្រើផលប្រយោជន៍ប្រជាពលរដ្ឋទូទៅ ក្នុងឃុំសង្កាត់ដោយស្មើភាព មិនរើសអើង និងសម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តន៍ក្នុងរង្វង់ដែនដីរបស់ខ្លួន។

ដីការឃុំ សង្កាត់មិនផ្ទុយនិងច្បាប់ ឬលិខិតបទដ្ឋាននានារបស់រដ្ឋឡើយ។ ដីការឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ទាំងមូល។

**ខ. សេចក្តីសម្រេចឃុំ សង្កាត់**

សេចក្តីសម្រេចឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តមួយដែលបង្កើតឡើង ដើម្បីអនុវត្តដីការរបស់ខ្លួន ឬលិខិតបទដ្ឋាននានារបស់រដ្ឋ ឬចែងអំពីការបង្កើត ការតែងតាំងការរៀបចំ ឬការគ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តន៍ក្នុងរង្វង់ដែនដីរបស់ខ្លួន។

**គ. កិច្ចការរដ្ឋបាល**

លិខិតរដ្ឋបាល គឺជាលិខិតដែលរៀបចំតាក់តែងឡើងជាលាយលក្ខណ៍អក្សរសម្រាប់ជាមធ្យោបាយទំនាក់ទំនងផ្លូវការរបស់រដ្ឋបាលឃុំ សង្កាត់ជាមួយស្ថាប័ន អង្គភាព និងបុគ្គលនានាក្នុង

គោលបំណងជូនព័ត៌មានណែនាំ អញ្ជើញ រាយការណ៍ ផ្សព្វផ្សាយ ឆ្លើយតប ឬតាក់តែង បុគ្គលណាមួយអោយទៅបំពេញបេសកម្ម។

លិខិតដែលរដ្ឋបាលឃុំ សង្កាត់ប្រើប្រាស់ជាផ្លូវការរួមមាន លិខិតស្នើ លិខិតជូនដំណឹង ឬសេចក្តីជូនដំណឹង លិខិតអញ្ជើញ លិខិតបញ្ជាបេសកម្ម របាយការណ៍ កំណត់ហេតុ លិខិតផ្ទេរសិទ្ធិ និងដីការអម។

- **លិខិតស្នើ៖** គឺជាលិខិតដែលឃុំ សង្កាត់ធ្វើឡើង ដើម្បីបង្ហាញពីគោលបំណង និងមូលហេតុនៃតម្រូវការជាក់លាក់ណាមួយរបស់ខ្លួន ថ្លែងទៅកាន់រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈ ឯកជន ក្រសួង ស្ថានប័ន អង្គការ ឬសង្គមស៊ីវិលដែលមានអំណាចសម្រេច ឬដោះស្រាយចំពោះការស្នើសុំនោះ។
- **សេចក្តីជូនដំណឹង៖** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើទំនាក់ទំនងជាមួយបុគ្គល ក្រសួង ស្ថាប័ន អង្គការស៊ីវិល មានខ្លឹមសារឆ្លើយតបបំភ្លឺបញ្ហា ឬជាការឆ្លើយតបចំពោះសំណើរ ឬការជូនដំណឹងអោយសាធារណៈជនបានដឹងនូវព័ត៌មាន ទាំងឡាយដែលឃុំ សង្កាត់ត្រូវការផ្សព្វផ្សាយ។
- **លិខិតអញ្ជើញ៖** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការអញ្ជើញបុគ្គល តំណាងក្រសួង ស្ថាប័ន អង្គការស៊ីវិលអោយចូលរួមក្នុងសកម្មភាពរបស់ឃុំ សង្កាត់ចំពោះកិច្ចការដែលទាក់ទងទៅនឹងបុគ្គល ឬអង្គភាពទាំងនោះដោយបញ្ជាក់ឈ្មោះ និងឋានៈ(អ្នកដែលត្រូវអញ្ជើញ) ទីកន្លែងប្រជុំ ឬពិធីប្រារព្ធ កាលបរិច្ឆេទកម្មវិធី ឬរបៀបវារៈប្រជុំ ។
- **លិខិតបញ្ជាបេសកម្ម៖** គឺជាលិខិតដែលឃុំ សង្កាត់ចាត់តាំងមន្ត្រី បុគ្គលិកឃុំ សង្កាត់អោយចូលរួមសកម្មភាពនានារបស់ឃុំ សង្កាត់។ លិខិតនេះភ្ជាប់មកជាមួយទិដ្ឋាការធ្វើដំណើរ។ ទិដ្ឋាការធ្វើដំណើរ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ឲ្យអ្នកដែលមានភារកិច្ចបំពេញបេសកម្ម យកទៅចុះទិដ្ឋាការនៅទីកន្លែង ការបរិច្ឆេទ មធ្យោបាយធ្វើដំណើរ និងហត្ថលេខារបស់អង្គភាពមានសមត្ថកិច្ចអនុញ្ញាត និងអង្គភាពដែលទទួលដឹងលឺអំពីការចេញដំណើរ និងការមកដល់ពីមួយដំណាក់មកមួយដំណាក់ទៀត។ នៅពេលត្រឡប់មកវិញត្រូវធ្វើរបាយការណ៍ ឬរាយការណ៍ជូនមេឃុំ ឬចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់ឲ្យបានដឹងអំពីលទ្ធផល ឬបញ្ហាសំខាន់ៗដែលខ្លួនបានទៅចូលរួម។
- **របាយការណ៍៖** គឺជាសេចក្តីរាយការណ៍អំពីសកម្មភាព ដំណើរការ និងលទ្ធផលការងារឃុំ សង្កាត់ ឬបុគ្គលិកណាម្នាក់ ឬមួយក្រុមដែលរដ្ឋបាលឃុំ សង្កាត់បានបំពេញ ឬឃុំ សង្កាត់បានចាត់តាំងអោយទៅបំពេញភារកិច្ចដើម្បីរាយការណ៍ជូនថ្នាក់ដឹងនាំ និងអង្គភាពពាក់ព័ន្ធ។

- **កំណត់ហេតុ៖** គឺជាការកត់ត្រាស្រង់យកមតិយោបលសេចក្ដីសម្រេច និងការឯកភាពលើសកម្មភាពដែលត្រូវបានអនុវត្តន៍ គ្រប់សមាជិកអង្គប្រជុំ ឬជាការកត់ត្រារាល់ហេតុការណ៍ណាមួយដែលបានកើតឡើងជាក់ស្ដែង ដើម្បីរក្សាទុកនៅពេលដែលមានតម្រូវការ។
- **លិខិតផ្ទេរសិទ្ធិ៖** គឺជាលិខិតរបស់មេឃុំ ចៅសង្កាត់ប្រកាសជាលាយលក្ខអក្សរប្រគល់សិទ្ធិឲ្យទៅជំទប់ ចៅសង្កាត់រងតាមឋានានុក្រមដើម្បីធ្វើជាមេឃុំ ចៅសង្កាត់ស្ដីទីអំឡុងពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន។
- **ដីការអមៈ** គឺជាឯកសាររដ្ឋបាលឃុំ សង្កាត់រៀបចំឡើងដើម្បី ផ្ញើអមភ្ជាប់ជាមួយសំណុំលិខិតដែលត្រូវផ្ញើចេញទៅអោយអង្គភាព ក្រសួង ស្ថាប័នណាមួយ ដោយមានការកត់ត្រាឈ្មោះ និងចំនួនលិខិតលើដីការអមនោះ។ ឃុំ សង្កាត់ប្រើដីការអមដើម្បីជៀសវាងការបាត់បង់ឯកសារដែលរដ្ឋបាលឃុំ សង្កាត់បានផ្ញើរចេញ។

### ១.២.២. ការគ្រប់គ្រងឯកសារ

ការគ្រប់គ្រងឯកសារ គឺជាការរៀបចំទុកដាក់ និងថែរក្សាឯកសារទាំងឡាយតាមប្រព័ន្ធមួយដែលមានសណ្ដាប់ធ្នាប់ និងសុវត្ថិភាព។

ការគ្រប់គ្រងឯកសាររបស់ ឃុំ សង្កាត់ផ្ដល់ផលប្រយោជន៍ដូចជា៖

- បង្ករលក្ខណៈងាយស្រួលក្នុងការស្វែងរកព័ត៌មាន និងទិន្នន័យសម្រាប់ដឹកនាំក្នុងការពិភាក្សារ និងការធ្វើសេចក្ដីសម្រេច
- ជួយបន្តចរន្តភាពព័ត៌មាននៅពេលមានអ្នកមកកាន់ការងារថ្មី និងអ្នកផ្លាស់ប្ដូរចេញ
- ផ្ដល់នូវភស្តុតាងជាក់លាក់ពីកិច្ចការ ឬព្រឹត្តិការណ៍ដែលកើតរួចហើយ
- បង្កើតប្រសិទ្ធិភាព និងសន្សំពេលវេលាដល់ការងាររដ្ឋបាលឃុំ សង្កាត់។

### ១.២.៣. ការគ្រប់គ្រងបុគ្គលិក

រដ្ឋបាលឃុំ សង្កាត់មានបុគ្គលិកពីរប្រភេទ គឺស្មៀនដែលរាជរដ្ឋាភិបាលបានបញ្ជូនមកឲ្យធ្វើការ និងបុគ្គលិកផ្ទាល់របស់សង្កាត់។ ស្មៀនសង្កាត់ពុំមានសិទ្ធិគ្រប់គ្រងទៅលើបុគ្គលិកផ្ទាល់របស់ក្រុមប្រឹក្សាសង្កាត់ទេ។ ករណីដែលក្រុមប្រឹក្សាសង្កាត់ និងស្មៀនសង្កាត់មិនចុះចម្រុងនឹងគ្នា ក្រុមប្រឹក្សាសង្កាត់មានសិទ្ធិស្នើសុំប្ដូរស្មៀនហើយក្រសួងមហាផ្ទៃត្រូវឆ្លើយតបជាវិជ្ជមានចំពោះការស្នើសុំនោះ។ ដូច្នេះ ការចាត់ចែងរបៀបនេះនាំឲ្យមានតុល្យភាពអំណាចរវាងក្រុមប្រឹក្សា និងស្មៀនសង្កាត់ ក្នុងការងាររដ្ឋបាលប្រចាំថ្ងៃ និងការធ្វើសេចក្ដីសម្រេចនានា។

ក្របខណ្ឌច្បាប់មិនបានចែងលំអិតអំពីប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សា សង្កាត់ទេច្បាប់គ្រាន់តែបញ្ជាក់ថាក្រុមប្រឹក្សាអាចជួយបុគ្គលិករបស់ខ្លួនផ្ទាល់ ស្ថិតនៅក្រោមការចាត់ចែង

សព្វថ្ងៃនេះក្រុមប្រឹក្សា ឃុំ សង្កាត់អាចជួយគណនេយ្យករឲ្យជួយគ្រប់គ្រងចំណូលដែលឃុំ សង្កាត់រកបាន។

### ១.២.៤. ការប្រព្រឹត្តទៅនៃកិច្ចការប្រជុំ

**ក. លិខិតអញ្ជើញ**

មេឃុំ ចៅសង្កាត់ត្រូវធានាថា លិខិតអញ្ជើញត្រូវបានរៀបចំ និងបានផ្ញើដល់អ្នកដែលត្រូវចូលរួមប្រជុំគ្រប់គ្នាទាំងអស់អោយបានមុនពេលប្រជុំ។

នៅក្នុងលិខិតប្រជុំត្រូវបញ្ជាក់អោយបានច្បាស់សាស់អំពី ពេលវេលា ទីកន្លែង និងបញ្ហាសំខាន់ដែលត្រូវពិភាក្សា ឬជំរាបនៅពេលប្រជុំ និងឯកសារពាក់ព័ន្ធដែលភ្ជាប់ជាមួយលិខិតអញ្ជើញ។

**ខ. ការបង្កើតរបៀបវារៈប្រជុំ**

គ្រប់ការប្រជុំទាំងអស់ត្រូវតែមានរបៀបវារៈ ហើយត្រូវផ្ញើដល់អ្នកចូលរួមជាមុន។ ចំនុចមួយចំនួនដែលយើងគួរលើកមកក្នុងការបង្កើតរបៀបវារៈរួមមានដូចជា៖

- ការងារដែលពិភាក្សា និងសម្រេច
- ព័ត៌មានដែលត្រូវជំរាប
- ពេលវេលាសម្រាប់ពេលប្រជុំ

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ច្រើនជាងមួយភាគបីអាចបន្ថែមប្រធានបទផ្សេងទៀត ដែលស្ថិតនៅក្រោមអំណាច និងមុខងាររបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ដើម្បីបញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។ ចំពោះចំនួនប្រជាពលរដ្ឋដែលអាចដាក់ស្នើបញ្ចូលបញ្ហាទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំសង្កាត់។

**គ. ការផ្សព្វផ្សាយអំពីកិច្ចប្រជុំសាធារណៈជន**

កាលបរិច្ឆេទ និងទីកន្លែងនៃកិច្ចប្រជុំត្រូវផ្សព្វផ្សាយជាសាធារណៈដោយបិទផ្សាយលើក្តាខៀនពត៌មានឃុំសង្កាត់ និងទីកន្លែងសាធារណៈក្នុងភូមិទាំងអស់ និងមធ្យោបាយផ្សព្វផ្សាយស្របតាមមូលដ្ឋានដែលមាននៅមូលដ្ឋាន[17]។

[17] សារណាបញ្ចប់ការសិក្សារបស់កញ្ញា រី ភីរ៉ា និង លោក រឿន ឧត្តម, ការគ្រប់គ្រងរដ្ឋបាលឃុំកោពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ,ឆ្នាំ២០១៨,ទំព័រ១៦

# ជំពូកទី២
# ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលសង្កាត់ចោមចៅ២

## ២.១ ស្ថានភាពភូមិសាស្ត្រ

សង្កាត់ចោមចៅទី២គឺជាសង្កាត់មួយដែលស្ថិតក្នុងចំណោមសង្កាត់ទាំង១៣ នៃខណ្ឌពោធ៍សែនជ័យ ដែលកាត់ចេញពីសង្កាត់ចោមចៅ តាមអនុក្រឹតលេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបំបែកសង្កាត់ចោមចៅជាបី គឺ សង្កាត់ចោមចៅទី១ សង្កាត់ចោមចៅទី២ និងសង្កាត់ចោមចៅទី៣។

សង្កាត់ចោមចៅទី២ គឺជាសង្កាត់ មួយក្នុងចំណោមសង្កាត់សរុប១៣ នៃ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដែលមានព្រំប្រទល់ ដូចខាងក្រោម៖

-ខាងជើង មានព្រំប្រទល់ ជាប់ សង្កាត់ កាកាបទី១

-ខាងកើត មានព្រំប្រទល់ជាប់ សង្កាត់ចោមចៅទី១

-ខាងត្បូងមានព្រំប្រទល់ជាប់ សង្កាត់ពងទឹក និង សង្កាត់ភ្លើងឆេះរទេះ

-ខាងលិចមានព្រំប្រទល់ជាប់ សង្កាត់ចោមចៅទី៣ និង សង្កាត់ភ្លើងឆេះរទេះ សង្កាត់កន្ទោក។

សង្កាត់ចោមចៅទី២ មានផ្ទៃដីសរុបចំនួន ១,០៣៤ គីឡូម៉ែត្រការ៉េ ក្នុងនោះដីលំនៅដ្ឋានមានចំនួន ៩៦៦ហិចតា ដីកសិកម្មចំនួន ៧៣ហិចតា។ មានភូមិនៅក្នុងដែនសមត្ថកិច្ចដើម្បីធ្វើការគ្រប់គ្រងចំនួន ១៦ភូមិ និង ៨សហគមន៍ ដែលបានផ្លាស់មកពីតំបន់បឹងកក់ចាស់ តំបន់ដីក្រហម និងតំបន់បុរីកីឡាចាស់។ មានប្រជាពលរដ្ឋក្នុងមូលដ្ឋានសរុបចំនួន ៣៩,១៧០នាក់ ស្ត្រីចំនួន ១៨,៩៣៨ នាក់ ត្រូវនឹង ៦,៤២២គ្រួសារ ហើយមានដងស៊ីតេប្រជាពលរដ្ឋ ៥២៣នាក់ក្នុងមួយម៉ែតការ៉េ។

សង្កាត់ចោមចៅទី២ មានសណ្ឋានដីលក្ខណៈរាបស្មើមិនលិចទឹក ដែលជាតំបន់កសិកម្ម សិប្បកម្ម សេវាកម្ម ដែលក្នុងនោះប្រជាពលរដ្ឋប្រកបមុខរបរកសិកម្ម ២,៧% សេវាកម្ម ៩,៦% សិប្បកម្ម ១,៣% កម្មករ,កម្មការនីរោងចក្រ បុគ្គលិកអង្គការចំនួន ៦៨,១% និងមន្ត្រីរាជការ ៦,៩% និងប្រកបមុខរបរដាំដំណាំរួមផ្សំផ្សេងៗទៀតដូចជា៖ ដាំស្ពៃ បណ្តុះផ្សិត ល្ពៅ ត្រកួន និងមួយចំនួនទៀតចិញ្ចឹមសត្វដូចជា៖ គោ ក្របី ជ្រូក មាន់ ទា ដើម្បីរួមផ្សំក្នុងការដោះស្រាយជីវភាពគ្រួសារប្រចាំថ្ងៃ[18]។

នៅក្នុងនោះក៏មានផ្លូវឆ្លងកាត់ភូមិ មានផ្លូវគ្រប់ប្រភេទ មានប្រវែង២៧,៧០០គីឡូម៉ែតនិងផ្លូវកាត់រាជធានី ខណ្ឌដែលឆ្លងកាត់សង្កាត់ប្រវែង ១២,០០៧គីឡូម៉ែត។ ហើយបច្ចុប្បន្នផ្លូវលំតាមបណ្តាលភូមិមួយចំនួន បានប្រែក្លាយទៅជាផ្លូវបេតុង ដែលមានលក្ខណៈងាយស្រួលច្រើនដល់

[18] សៀវភៅវិភាគសេដ្ឋកិច្ចរបស់សង្កាត់ចោមចៅទី២

ប្រជាពលរដ្ឋក្នុងការធ្វើដំណើរ នៅក្នុងភូមិក៏ដូចជាប្រជាពលរដ្ឋទូទៅដែលបានឆ្លងកាត់ ក្រោយពីសង្កាត់មានធនធានថវិកាដែលរាជរដ្ឋាភិបាលបានវិភាជន៍ឲ្យមកអភិវឌ្ឍន៍មូលដ្ឋានដោយផ្ទាល់ ហើយផ្លូវដែលនៅសេសសល់ទៀតពុំទាន់មានការអភិវឌ្ឍន៍នៅឡើយទេ មានផ្លូវខ្លះលិចទឹក នៅរដូវវស្សា និងដីហុយនៅរដូវប្រាំងជាហេតុនាំអោយមានការប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋ។ ការជួសជុលផ្លូវធម្មតាក៏មិនធានាគុណភាពដែរ ទាមទារចាំបាច់ត្រូវតែជួសជុលផ្លូវជាលក្ខណៈបេតុងតាមភូមិ បើពិនិត្យលើសក្តានុពលដែលទទួលបាននោះ គឺមិនឆ្លើយតបបានទេ មានតែការចូលរួមពីសាលារាជធានីភ្នំពេញ មន្ទីរ អង្គភាព សប្បុរសជន និងប្រជាពលរដ្ឋទើបសម្រេចបានលទ្ធផលដូចសព្វថ្ងៃនេះ ហើយវិភាជន៍ពីរាជរដ្ឋាភិបាលដែលបានផ្តល់អោយសង្កាត់នៅមានកម្រិតពុំអាចសម្រេចទៅតាមសំនូមពររបស់ប្រជាពលរដ្ឋគ្រប់ភូមិបានទេ។

### ២.១.១ កសិកម្ម

សង្កាត់ចោមចៅទី២ មានផ្ទៃដីបង្កបង្កើនផលស្រូវរដូវវស្សាចំនួន ៨៦ហិកតា ទិន្នផលទទួលបាន ០២តោនក្នុងមួយហិកតា។ គ្រួសារមានមុខរបរធ្វើស្រែជាចំបងមាន២.៧% គ្រួសារមានមុខរបរចិញ្ចឹមគោមាន០.៩% គ្រួសារមានមានមុខរបរចិញ្ចឹមសត្វមាន់៨.១% គ្រួសារមានមុខរបរចិញ្ចឹមសត្វទា០.៣%។ ខាងលើនេះជាសក្តានុពលស្រូបទាញនូវកម្លាំងពលកម្ម និងចំណូលមួយភាគធំសម្រាប់ទ្រទ្រង់ក្នុងវិស័យសេដ្ឋកិច្ច និងវិស័យសេវាកម្មមានរហូតដល់៩៦%។ ទន្ទឹមនឹងនោះសក្តានុពលខាងលើក៏មានបញ្ហាប្រឈមដែលកើតមានក្នុងវិស័យសេវាកម្មនេះផងដែរគឺ ការងារមិនជាប់លាប់ជាប្រចាំនោះទេ។

ប្រជាពលរដ្ឋ ប្រកបមុខរបរចំបងក្រៅពីវិស័យសេវាកម្ម គឺពួកគាត់មានមុខរបរចម្បងផ្សេងទៀតគឺ ផ្នែកផលិតកម្ម សិប្បកម្ម កសិកម្ម ដែលជាសក្តានុពលយ៉ាងខ្លាំង ក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងសង្កាត់ទាំងមូល។

### ២.១.២ ស្ថានភាពសង្គមកិច្ច

#### ក. វិស័យសុខាភិបាល

សង្កាត់ចោមចៅទី២ មានសេវាសុខាភិបាលរបស់រដ្ឋ ចុះដល់មូលដ្ឋានតាមរយៈការចាក់ថ្នាំបង្ការ ផ្សព្វផ្សាយការពារជម្ងឺឆ្លងរបស់ការិយាល័យសុខាភិបាល គួបផ្សំសេវាឯកជន មានគ្លីនិកឯកជនចំនួនមួយកន្លែង ឪសថស្ថាន និងឪសថស្ថានរងចំនួន០៣កន្លែង រួមមានវេជ្ជបណ្ឌិត ទន្តបណ្ឌិត គ្រូពេទ្យ ឪសថការី គិលានុបដ្ឋាក ពេទ្យធ្មេញ និងការទទួលបានសេវាជាតិលើកកម្ពស់សុខភាពជារៀងរាល់ឆ្នាំ មានភ្នាក់ងារសុខាភិបាល ចុះអប់រំតាមបណ្តាលភូមិទាំង១៦ ក្នុងសង្កាត់ពីបញ្ហាសុខភាពប្រជាជន។

**ខ. វិស័យអប់រំ**

សង្កាត់ចោមចៅទី២ មានគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនគ្រប់កម្រិតរួមមានៈអនុវិទ្យាល័យ បឋមសិក្សា និងមត្តេយ្យសិក្សាដែលមាន៣៥កន្លែង មានសិស្សចូលរៀនចំនួន៨៥២នាក់ និងបឋមសិក្សាមាន០២កន្លែង មានសិស្សចូលរៀន ២.៥៩៦នាក់ និងអនុវិទ្យាល័យចំនួន០១ ដែលមានសិស្សចូលរៀនចំនួន១.១៩៥នាក់ នៅតាមភូមិបង្កការងាយស្រួលដល់ការសិក្សាសិស្សានុសិស្សឲ្យទទួលបានសេវាការអប់រំ។

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ មន្ត្រីអប់រំ លោកគ្រូ/អ្នកគ្រូគ្រប់កម្រិត បានខិតខំប្រឹងប្រែងដើម្បីឆ្លើយតបទៅនឹងគោលនយោបាយអប់រំជាតិ(ការអប់រំសម្រាប់អ្នកទាំងអស់គ្នា ទាំងអស់គ្នាដើម្បីការអប់រំ) អោយបានសម្រេចប្រកបដោយគុណភាព និងប្រសិទ្ធភាពនៅឆ្នាំ២០២២។

ផ្អែកតាមលទ្ធផលជាក់ស្តែងក្នុងឆ្នាំ២០១៦បានបង្ហាញថាៈ

- កុមារអាយុចាប់ពី ៣ទៅ៥ឆ្នាំ បានចូលរៀនសាលាមត្តេយ្យសិក្សាចំនួន៩២.៨%
- កុមារអាយុ ៦ ឆ្នាំបានចូលរៀនសាលាបឋមសិក្សា ចំនួន ១០០%
- កុមារអាយុ ៦ ដល់១១ ឆ្នាំបានចូលរៀនបឋមសិក្សាចំនួន ១០០%
- កុមារអាយុចាប់ពី ១២ ដល់ ១៤ឆ្នាំបានចូលរៀន( បឋមនិងអនុ) ចំនួន៩៩.៩៥%
- កុមារអាយុ ១៥ ដល់១៧បានចូលរៀន១០០%

ពិតមែនតែលទ្ធផលខាងលើបានបង្ហាញពីការរីកចម្រើនក្នុងឆ្នាំកន្លងមក។ ប៉ុន្តែមិនទាន់ឆ្លើយតបទៅនឹងចំណុចថ្នាក់ជាតិនៅឡើយទេ ដោយសារតែបញ្ហាប្រឈមមួយចំនួនដែលជាឧបសគ្គក្នុងការអនុវត្តដូចជាៈ កម្រិតជីវភាពរបស់ប្រជាពលរដ្ឋមួយចំនួនមានការលំបាក តម្រូវការកម្លាំងកូនជួយការងារផ្ទះ ជួយប្រកបមុខរបរទ្រទ្រង់ជីវភាពគ្រួសារ និងបម្លាស់ទីលំនៅដ្ឋានមកប្រកបមុខរបរការងារ(កម្មកររោងចក្រ កម្មករសំណង់...)

**គ. វិស័យសាសនា**

នៅក្នុងសង្កាត់ចោមចៅទី២ មានវត្តអារាមចំនួន០២ ជាទីកន្លែងគោរពសក្ការៈរបស់ព្រះពុទ្ធបរិស័ទ និងប្រជាពលរដ្ឋគោរពបូជា តាមទំនៀមទំលាប់ព្រះពុទ្ធសាសនា ប៉ុន្តែវត្តទាំង ០២នេះនៅមានកន្លែងខ្វះខាតច្រើន ក្នុងការកសាងសមិទ្ធិផលថ្មីៗបន្ថែមទៀត ក្នុងការបម្រើវិស័យព្រះពុទ្ធសាសនា ព្រមទាំងវិហារគ្រឹស្តសាសនាចំនួន០២ នៅមូលដ្ឋានសង្កាត់ផងដែរ។

**ឃ.ការងារយេនឌ័រ**

ក្នុងបរិបទការងារយេនឌ័រ នៃការអភិវឌ្ឍន៍នៃការរីកចម្រើនរបស់សង្គមជាតិ បច្ចុប្បន្នតួនាទីស្ត្រីត្រូវបានលើកម្ពស់ក្នុងគ្រប់រចនាសម្ព័ន្ធសង្គមទាំងមូល ពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋានភូមិ។

ស្ត្រីក្នុងតំណាក់កាលថ្មីបានខិតខំពង្រឹងទាំងចំណេះដឹង ទាំងសមត្ថភាព ក្លាយជាធនធានរបស់សង្គមយ៉ាងរឹងមាំ និងជាចលករដ៏សំខាន់ក្នុងបុព្វហេតុការងារអភិវឌ្ឍន៍ និងការលើកកម្ពស់សីលធម៌សង្គម ។

ទន្ទឹមនឹងនេះក៏មានស្ត្រីមួយចំនួននៅតែប្រឈមទៅនឹងអំពើហឹង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី ការរំលោភផ្លូវភេទ ការសេពគ្រឿងញៀន ការប្រព្រឹត្តល្បែងស៊ីសង បានផ្តើមចេញពីការមិនគោរពសិទ្ធកាតព្វកិច្ចក្នុងរង្វង់គ្រួសារ ចាញ់ការបោកប្រាស់ពីសំណាក់ជនខិលខូច អស្ថេរភាពក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ការទទួលយកវប្បធម៌ពាលាអាវ៉ាសែ ដែលតម្រូវអោយស្ត្រីទាំងអស់ គប្បីមានវិធានការអប់រំទប់ស្កាត់កុំអោយមានបញ្ហាទាំងនោះកើតមានឡើង ។

**ង.ស្ថានភាពនៃភាពក្រីក្រ**

បញ្ហាភាពក្រីក្រនៅតែមានបណ្តាលមកពីមូលហេតុខាងក្រោម៖

-គ្រួសារធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារធ្វើ និងមានចំណូលតិចតួច

-គ្មានផ្ទះសម្បែងស្នាក់នៅ (ជួលផ្ទះគេ) និងមានសមាជិកច្រើន

-គ្មានមុខរបបរពិតប្រាកដ និងរៀនបានតិចតួចពុំមានជំនាញវិជ្ជាជីវៈ

-គ្រួសារជួបវិបត្តិលែងលះគ្នា និងមានអំពើហិង្សា

នៅចុងឆ្នាំ២០១៥ ក្រោយពីមានការជួយឧបត្ថមពីអង្គការ GIZ និងមានការចូលរួមបដិភាគពីរាជរដ្ឋាភិបាល ក្រសួងផែនការ សហការជាមួយរដ្ឋាភិបាលក្រុងភ្នំពេញ រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ បាននឹងកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ដើម្បីផ្តល់មូលនិធិសមធមិជូនប្រជាពលរដ្ឋ ហើយក្រោយមកទៀត រាជរដ្ឋាភិបាលដែលមានក្រសួងផែនការជាសេនាធិការ និងប្រើថវិការាជរដ្ឋាភិបាលបានធ្វើបច្ចុប្បន្នភាព និងកំណត់អត្តសញ្ញាណគ្រួសារក្រីក្រជាលើកទីពីរ ដើម្បីផ្តល់មូលនិធិសមធមិជូនប្រជាពលរដ្ឋទៅតាមសង្កាត់។

## ២.២ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់សង្កាត់

សង្កាតគឺជានីតិបុគ្គលសារធារណៈ ដែលមានធនធានសម្រាប់ដំណើរការសកម្មភាពរបស់ខ្លួន។ បើយោងទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តម្រូវអោយឃុំ សង្កាត់នីមួយៗមានធនធានហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន[19]។ ហើយរដ្ឋបាលឃុំ សង្កាត់មានសិទ្ធិអំណាចគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន និងមានប្រភពចំណូល និងចំណាយមួយចំនួនទៀតផងដែរ។

[19] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៧៣

### ២.២.១ ការរៀបចំ និងការអនុម័តថវិកាសង្កាត់

ការរៀបចំឡើងដោយក្រោមការទទួលខុសត្រូវរបស់ចៅសង្កាត់ និងដោយមានជំនួយពីគណៈកម្មាធិការកសាងផែនការ និងថវិកាសង្កាត់ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិនិត្យ និងអនុម័ត។ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តគម្រោងថវិកានៃកិច្ចប្រជុំ ជាសាធារណៈ។

ចំពោះសង្កាត់ចោមចៅទី២មុននិងរៀបចំថវិកា សង្កាត់តែងតែធ្វើប្រឹក្សាយោបល់ពីប្រជាពលរដ្ឋអំពីតម្រូវការរបស់ពួកគាត់ ដើម្បីងាយស្រួលរៀបចំថវិការអោយត្រូវតាមទិសដៅដែលប្រជាពលរដ្ឋនៅក្នុងសង្កាត់ចង់បាន និងបានអោយប្រជាពលរដ្ឋផ្តិតមេដៃចូលរួមចំណែកក្នុងការដឹងឮផងដែរ។ បន្ទាប់ពីការអនុម័តគម្រោងថវិកាសង្កាត់រួចរាល់មក ចៅសង្កាត់ចោមចៅទី២ក៏ចាប់ផ្តើមបញ្ជូនគម្រោងថវិកានោះទៅកាន់អភិបាលក្រុងភ្នំពេញ។ ក្រោយពីអភិបាលក្រុងបានធ្វើការឯកភាពលើគម្រោងនេះហើយ លោកក៏បញ្ជូនសេចក្តីជូនដំណឹងជាលាយលក្ខ័អក្សរជូនត្រឡប់ទៅចៅសង្កាត់វិញ ដើម្បីបញ្ជាក់ពីការទទួលស្គាល់គម្រោងថវិកាដែលសេចក្តីជូនដំណឹងនេះក៏មានចម្លងជូន និងភ្ជាប់ជាមួយគម្រោងថវិការទៅអោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគារក្រុងផងដែរ។

### ២.២.២ ចំណូល និងចំណាយថវិការ

#### ក.ប្រភពចំណូល

ឃុំ សង្កាត់មានប្រភពចំណូលចំនួនបី គឺចំណូលផ្ទាល់ ចំណូលមកពីមូនិធិឃុំ សង្កាត់ និងចំណូលមកពីការអនុវត្តមុខងារ។

- **ចំណូលផ្ទាល់៖** ឃុំ សង្កាត់មានសិទ្ធិប្រមូលចំណូលផ្ទាល់ដែលបានមកពីសារពើពន្ធ និងចំណូលមិនមែនជាសារពើពន្ធនៅក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន។
- **ចំណូលមកពីមូលនិធិឃុំ សង្កាត់៖** ចំណូលមូលនិធិឃុំ សង្កាត់គឺ ជាការផ្ទេរធនធានពីមូលនិធីឃុំ សង្កាត់ទៅឲ្យឃុំ សង្កាត់នីមួយៗក្នុងនោះរួមមាន ចំណូលសម្រាប់រដ្ឋបាល និងចំណូលសម្រាប់អភិវឌ្ឍន៍ឃុំ សង្កាត់[20]។
- **ចំណូលបានមកពីអនុវត្តមុខងារជាភ្នាក់ងារ៖** ចំណូលដែលបានមកពីអនុវត្តមុខងារជាភ្នាក់ងារគឺជាចំណូលដែលបានមកពី ការបំពេញការងារដោយឃុំ សង្កាត់ ជំនួសមុខឲ្យក្រសួង ស្ថាប័ន ឬអង្គភាពរបស់រដ្ឋទៅតាមការព្រមព្រៀង។

ក្រៅពីចំណូលទាំងបីខាងលើនេះ ឃុំ សង្កាត់គឺមានចំណូលផ្សេងៗទៀតដូចជា ចំណូលពីការរួមចំណែកពីប្រជាពលរដ្ឋ ចំណូលពីអង្គការមិនមែនរដ្ឋាភិបាល និងចំណូលពីកម្មវិធីនានា។ នៅ

[20] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៧៨

ចំពោះមុខច្បាប់ចំណូលថវិកាឃុំ សង្កាត់នេះត្រូវទទួលខុសត្រូវការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិ ដើម្បីធានាអោយការប្រើប្រាស់ធនធានអោយបានត្រឹមត្រូវ តម្លាភាពសន្សំសំចៃ និងមានប្រសិទ្ធិភាពខ្ពស់។

**ខ.ការចំណាយរបស់សង្កាត់**

សង្កាត់មានការចំណាយពីរគឺ ចំណាយចរន្ត និងចំណាយមូលធន។

- **ចំណាយចរន្ត៖** ចំណាយចរន្តមានប្រាំពីរប្រភេទគឺ ចំណាយប្រាក់បៀវត្ស ប្រាក់បំណាច់ឆ្នាំ ចំណាយរដ្ឋបាលទូទៅ ចំណាយសេវាសាធារណៈ ចំណាយសម្រាប់មុខងារជាភ្នាក់ងារ ចំណាយអន្តរាគមន៍សេដ្ឋកិច្ច និងចំណាយមិនបានគ្រោងទុក។
- **ចំណាយមូលធន៖** ចំណាយមូលធនមានពីរប្រភេទគឺ ចំណាយរដ្ឋបាល និងការអភិវឌ្ឍន៍។ ចំណាយរដ្ឋបាលគឺជាការចំណាយប្រតិបត្តិការ និងវិនិយោគដោយរដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តន៍ភារកិច្ចរួមមាន ប្រាក់បំណាច់សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ បៀវត្សមន្ត្រីសង្កាត់ ប្រាក់សម្រាប់ការទិញ ឬជួសជុល និងសម្រាប់ក្រុមប្រឹក្សាសង្កាត់ ទិញសង្ហារឹមសម្ភារៈ មធ្យោបាយរដ្ឋបាល ការជួសជុល និងថែទាំមធ្យោបាយរដ្ឋបាល ថ្លៃទឹកភ្លើង និងការចំណាយផ្សេងៗទៀត។

  ចំណែកឯការអភិវឌ្ឍន៍វិញ គឺជាការចំណាយទៅលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងការផ្តល់សេវាសង្គមកិច្ចដែលក្នុងនោះរួមមាន ការសាងសង់ ជួសជុល ការថែទាំផ្លូវ ផ្សារ មណ្ឌលសុខភាព សាលារៀន ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធផ្គត់ផ្គង់ទឹកថាមពល ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច មន្ត្រីបុគ្គលិក កិច្ចការខាងលើ កម្មវិធីអភិឌ្ឍន៍សហគមន៍ បរិស្ថាន និងធម្មជាតិជាដើម។

### ២.២.៣ ប្រព័ន្ធទូទាត់ គណនេយ្យ និងកិច្ចការលទ្ធកម្ម ឃុំ សង្កាត់

**ក.គោលការណ៍ទូទៅ**

ឃុំ សង្កាត់ត្រូវបង្កើតគណនីប្រាក់បញ្ញើនៅរតនាគាគ្រប់ខេត្តក្រុង[21]។ ហើយមេឃុំ ចៅសង្កាត់ជាអាណាប័ក និងមានសិទ្ធិពេញលេញលើការប្រមូល ឬសន្យាចំណាយ និងបញ្ជាចំណាយដែលផ្អែកលើថវិកាដែលបានអនុម័ត។ មេឃុំ ចៅសង្កាត់អាចផ្ទេរសិទ្ធិក្នុងការសម្រេចលើថវិកាទៅអោយជំទប់ ឬចៅសង្កាត់រងរបស់រដ្ឋបាលឃុំ សង្កាត់។ ការផ្ទេរសិទ្ធិអាណាប័កនេះ ត្រូវធ្វើសកម្មភាពដោយស្ថិតក្នុងការទទួលខុសត្រូវ និងត្រួតពិនិត្យរបស់មេឃុំចៅសង្កាត់។ មេឃុំចៅសង្កាត់ និងអ្នក

[21] អនុក្រឹត្យលេខ២៦ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់,មាត្រា២៩

ទទួលខុសត្រូវតម្កល់គម្រូហត្ថលេខាជាផ្លូវការដល់គណនេយ្យករមុខការ[22]។ ហើយអ្នកទទួលសិទ្ធិ និងបុគ្គលិករដ្ឋបាលឃុំ សង្កាត់ជាទូទៅមិនអនុញ្ញាតអោយកាន់កាប់មូលនិធិ ឬធ្វើការទូទាត់ចំណាយ លើកលែងតែក្នុងករណីទូទាត់បេឡាបុរេប្រទាន និងចំណូលដែលប្រមូលបាន ដោយភ្នាក់ងារប្រមូលចំណូល។ លើសពីនេះទៅទៀតសិទ្ធិបញ្ជាចំណាយ និងទូទាត់មិនត្រូវប្រគល់អោយមនុស្សតែម្នាក់ឡើយហើយរតនាគារខេត្តក្រុង ត្រូវបំពេញមុខងារជាគណនេយ្យករឃុំ សង្កាត់។

**ខ. ប្រព័ន្ធទូរទាត់**

ការទូរទាត់ផ្ទាល់ គឺជាការទូរទាត់តាមរយៈរតនាគារខេត្ត ក្រុង ហើយការទូទាត់តាមរយៈ បេឡាបុរេប្រទានត្រូវប្រើតែចំណាយចរន្ត (លើកលែងតែប្រាក់បៀវត្ស និងប្រាក់ចំណាច់) និងការចំណាយវិនិយោគរដ្ឋបាល។ ហើយការចំណាយមួយលើកៗ ចេញពីបេឡាបុរេប្រទានត្រូវមានចំនួនទឹកប្រាក់នៅក្រោមកម្រិតមួយជាកំណត់ តាមនីតិវិធីបេឡាបុរេប្រទាន[23]។

[22] អនុក្រឹត្យលេខ២៦ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់,មាត្រា២៧

[23] អនុក្រឹត្យលេខ២៦ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់,មាត្រា៣១

# ជំពូកទី៣
# ផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល

## ៣.១ ក្របខណ្ឌអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ

ក្រុមប្រឹក្សាសង្កាត់បានរៀបចំផែនការអភិវឌ្ឍន៍៥ឆ្នាំនេះឡើង ដើម្បីប្រមូលផ្តុំនូវសេចក្តីត្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានសង្កាត់ និងគៀរគរធនធាននានាក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការជាអាទិភាពទាំងនោះ ដែលចូលរួមចំណែកដោយផ្ទាល់ដល់ជីវភាពរស់នៅសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ ផែនការអភិវឌ្ឍន៍សង្កាត់នេះ ត្រូវបានប្រើប្រាស់ជាមូលដ្ឋាននៃការរៀបចំផែនការវិនិយោគ និងថវិកាប្រចាំឆ្នាំរបស់សង្កាត់ផងដែរ។

### ៣.១.១ ចក្ខុវិស័យអភិវឌ្ឍន៍

សង្កាត់ចោមចៅទី២ មានការអភិវឌ្ឍន៍លើគ្រប់វិស័យ ប្រជាពលរដ្ឋមានជីវភាពធូរធារ សមរម្យរស់នៅក្នុងស្ថានភាពល្អ ប្រកបដោយសុវត្ថិភាព សុខុមាលភាព សេដ្ឋកិច្ចថ្លៃថ្នូរ និងមានសុខសុវត្ថិភាព។

គោលបំណងនៃការអភិវឌ្ឍន៍ត្រូវសរសេរដោយផ្អែកតាមតម្រូវការ និងឧបសគ្គដែលត្រូវរៀបរាប់ក្នុងសូចនាករទាំង៩ ខាងក្រោមៈ

១). លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លាន

២). សម្រេចអោយបានការអប់រំមូលដ្ឋានជាទូទៅរយៈពេល៩ឆ្នាំ

៣). លើកកម្ពស់សមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី

៤). កាត់បន្ថយអត្រាមរណៈភាពកុមារ

៥). លើកកម្ពស់សុខភាពមាតា

៦). ប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺដ៏ទៃទៀត

៧). ធានានិរន្តភាពបរិស្ថាន

៨). បង្កើតភាពជាដៃគូរជាសកលសម្រាប់កិច្ចអភិវឌ្ឍន៍ និង

៩). ការដោះមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះ។

### ៣.១.២ គោលដៅអភិវឌ្ឍន៍

ដោយអាណត្តិក្រុមប្រឹក្សា សង្កាត់មានរយៈពេល៥ឆ្នាំដូចនេះ សង្កាត់ត្រូវរៀបចំគោលដៅអភិវឌ្ឍន៍របស់ខ្លួនដែលអាចសម្រេចបានក្នុងរយៈពេល៥ឆ្នាំ។ គោលដៅអភិវឌ្ឍន៍ត្រូវសរសេរផ្អែកតាមសេចក្តីត្រូវការអភិវឌ្ឍន៍ដែលបានសរសេរខាងលើ។ សង្កាត់ត្រូវកំណត់គោលដៅអភិវឌ្ឍន៍របស់ខ្លួន ដោយពិចារណាថ្លឹងថ្លែងរវាងទំហំនៃសេចក្តីត្រូវការទៅនឹងលទ្ធភាពធនធានដែលអាចមាន និង

សមត្ថភាពអនុវត្តន៍ដើម្បីកំណត់ពីទំហំសួចនាករតាមគោលដៅអភិវឌ្ឍន៍នីមួយៗ អាចសម្រេចបាន ក្នុងអាណត្តិក្រុមប្រឹក្សាសង្កាត់។

**៣.១.៣ យុទ្ធសាស្ត្រអភិវឌ្ឍន៍**

ផ្អែកតាមគោលដៅអភិវឌ្ឍន៍ សង្កាត់ដែលបានសរសេរក្នុងចំណុចខាងលើ សង្កាត់ត្រូវកំណត់យុត្តិសាស្ត្ររបស់ខ្លួន ដើម្បីឈានទៅសម្រេចនូវគោលដៅអភិវឌ្ឍន៍ សង្កាត់ទាំងនោះ។ យុត្តិសាស្ត្រនេះគឺជាវិធី ឬមធ្យោបាយនានាដែលគ្រោងអនុវត្ត ហើយផលដែលទទួលបានពីការអនុវត្តទាំងនោះនាំអោយសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ដែលបានកំណត់។ យុត្តិសាស្ត្រអភិវឌ្ឍន៍ មានជាអាទិ៍ យុត្តិសាស្ត្រអភិវឌ្ឍន៍ផ្លូវថ្នល់ ប្រព័ន្ធទឹក ប្រព័ន្ធអគ្គិសនី អប់រំ សុខភាព គ្រប់គ្រងដីធ្លី គ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន បំណិនជីវិត សុវត្ថិភាព លើកកំពស់ស្ថានភាពស្ត្រី និងជនងាយរងគ្រោះ-ល-។

**ក. យុត្តិសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច**

យុត្តិសាស្ត្រនៃការអភិវឌ្ឍន៍សង្កាត់ចោមចៅទី២ នេះមានគោលបំណងចំនួន៤ធំៗ គឺទី១ មានគោលបំណងអភិវឌ្ឍន៍វិស័យគមនាគមន៍ ដែលក្នុងនោះធ្វើយ៉ាងណាអោយមានប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍ និងប្រព័ន្ធអគ្គិសនីបំភ្លឺនៅតាមផ្លូវសាធារណៈ។ ទី២ មានគោលបំណងអភិវឌ្ឍន៍ពាណិជ្ជកម្ម សំដៅដល់គុនភាពចំណីអាហារបម្រើអោយសុខភាពប្រជាជននៅក្នុងមូលដ្ឋាន។ ទី៣ មានគោលបំណងអភិវឌ្ឍន៍លើវិស័យឧស្សាហកម្ម និងសិប្បកម្ម រួមមានសិប្បកម្មបច្ចេកទេសទំនើប សិប្បកម្មមានច្បាប់អនុញ្ញាតត្រឹមត្រូវ ហើយនៅមានសុពលភាព។ និងទី៤ មានគោលបំណងអភិវឌ្ឍន៍វិស័យអភិវឌ្ឍន៍ សំដៅព័ត៌មានអំពីស្ថានភាពសង្កាត់ ទិន្នន័យភូមិប្រកប ដោយគុណភាព។

**ខ. យុត្តិសាស្ត្រអភិវឌ្ឍន៍ សង្គមកិច្ច**

ប្រជាពលរដ្ឋទទួលបាននូវសេវាសុខភាព មានចំណេះដឹងកាន់តែប្រសើរឡើង និងរស់នៅក្នុងសេចក្តីថ្លៃថ្នូរ។ ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ចនេះត្រូវបានបែងចែកចេញជាប្រាំមួយវិស័យសម្រាប់អភិវឌ្ឍន៍។ ទី១ គោលបំណងអភិវឌ្ឍន៍វិស័យសុខាភិបាល គឺសេវាថែទាំសុខភាព និងការព្យាបាលអ្នកជំងឺគ្រប់ប្រភេទដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ សាសនាអ្វីឡើយ។ ទី២ អភិវឌ្ឍន៍លើវិស័យអប់រំ គឺធ្វើយ៉ាងណាអោយគុណភាពអប់រំកាន់តែល្អប្រសើរ និងធ្វើខ្លួនអោយក្លាយទៅជាសិស្សល្អ និងលុបបំបាត់អក្ខរភាព។ ទី៣ វិស័យសាសនា៖ ប្រជាពលរដ្ឋមានវត្តអារាមសម្រាប់គោរពបូជា ពង្រឹងការគោរពបដិបត្តិធម៌វិន័យព្រះពុទ្ធសាសនា។ ទី៤វិស័យព័ត៌មាន ធ្វើយ៉ាងណាអោយប្រជាជនទទួលបានព័ត៌មានទាន់ពេលវេលា និងទាន់ហេតុការណ៍។ ទី៥ ខាងផ្នែកវិស័យយេនឌ័រ៖ គ្រួសារមានសុភមង្គល និងការលើកកម្ពស់សមភាពយេនឌ័រ និងតម្លៃស្ត្រីខ្មែរ។ និងទី៦

វិស័យសង្គមកិច្ចៈ សមាគមមនុស្សចាស់ និងពង្រឹងការគ្រប់គ្រង ឬសហការជាមួយអង្គការសង្គមស៊ីវិល។

**គ. យុត្តិសាស្ត្រការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ**

**- ការគ្រប់គ្រងដីធ្លី**

មានច្បាប់ភូមិបាលឆ្នាំ២០០១ និងមានអនុក្រឹត្យលេខ៨៦ ស្តីពីការគ្រប់គ្រងសំណង់ មានយន្តការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ និងសេចក្តីណែនាំ និថលិខិតបទដ្ឋានជាច្រើនសម្លាប់ធ្វើជាមូលដ្ឋានក្នុងការគ្រប់គ្រង់ដីធ្លី។

**- ការងារបរិស្ថាន**

ការប្រមូលសម្រាមជារៀងរាល់ថ្ងៃ ការគ្រប់គ្រងសំណង់រឹង ធ្វើអោយបរិស្ថានរស់នៅបានល្អអប់រំប្រជាពលរដ្ឋអោយចេះវេចខ្ចប់ទុកដាក់សម្រាម ចោទជាបញ្ហាការប្រមូលសំរាមយឺតយ៉ាវ និងចលនាប្រជាជនអោយយកចិត្តទុកដាក់ដាំផ្លែឈើហូបជុំវិញផ្ទះ ដើម្បីបង្កើតជីវភាពការពារបរិស្ថានធម្មជាតិ បញ្ហាប្រជាពលរដ្ឋមួយចំនួនមិនទាន់យល់ដឹងអំពីការគ្រប់គ្រងសម្រាមនៅតែចោលសម្រាមផ្តេសផ្តាស និងចោលរាយប៉ាយ រថយន្តស៊ីនទ្រីចូលមិនដល់នេះជាហេតុធ្វើអោយបរិស្ថាន និងការគ្រប់គ្រងសម្រាមមិនទាន់បានល្អនៅឡើយ។ ទើបសង្កាត់បានដាក់អនុវត្តនូវយុត្តិសាស្ត្រ ថ្មីដើម្បីកាត់បន្ថយផ្លូវលិចទឹក និងណែនាំប្រជាពលរដ្ឋអោយវេចខ្ចប់អោយបានត្រឹមត្រូវ និងកាត់បន្ថយការប្រើប្រាស់ថង់ប្លាសស្ទិកនិងវែកញែកអោយបានត្រឹមត្រូវ។

**ឃ. យុត្តិសាស្ត្រអភិវឌ្ឍន៍ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ**

បញ្ហាសន្តិសុខក្នុងមូលដ្ឋាន ជារឿងចាំបាច់ដែលទាក់ទងទៅនឹងសុវត្ថិភាពក្នុងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ អាជ្ញាធរសង្កាត់បានសហការជាមួយកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ ចុះល្បាតតាមគោលដៅសំខាន់ៗជារៀងរាល់ថ្ងៃដើម្បីគ្រប់គ្រងសភាពការណ៍ និងទប់ស្កាត់បទល្មើសផ្សេងៗដែលបម្រុងកើតមានឡើងធានារនូវសុវត្ថិភាព ។

**- គោលដៅអភិវឌ្ឍន៍វិស័យរដ្ឋបាល**

នៅឆ្នាំ២០២២រដ្ឋបាលសង្កាត់មានការយល់ដឹងអំពីលិខិតរដ្ឋបាល គ្រប់គ្រងប្រជាពលរដ្ឋក្នុងភូមិ ការគ្រប់គ្រងសាលាសង្កាត់ការរៀបចំកិច្ចប្រជុំ ការគ្រប់គ្រងឯកសារ និងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព។

- ពង្រឹងសមត្ថភាពក្រុមប្រឹក្សាសង្កាត់ និងមន្ត្រី
- ការពង្រឹងសមត្ថភាព ប្រធានភូមិ អនុភូមិ និងសមាជិកភូមិ
- បណ្តុះបណ្តាល/ប្រជុំ សិក្ខាសាលា/ហ្វឹកហ្វឺន/សម្របសម្រួល

- ផ្សព្វផ្សាយ អំពីនីតិវិធីការផ្តល់សេវាប្រជាពលរដ្ឋ

**- គោលដៅអភិវឌ្ឍន៍ វិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ**

នៅឆ្នាំ២០២២ សន្តិសុខសណ្តាប់ធ្នាប់សារធារណៈមានសណ្តាប់ធ្នាប់ល្អ ដោយប្រជាពលរដ្ឋយល់ដឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឈប់ប្រើប្រាស់ផ្លូវនឹងចិញ្ចើមផ្លូវធ្វើអាជីវកម្ម និងការចតយានយន្តគ្រប់គ្រងប្រភេទ មានសៀវភៅគ្រួសារ និងអត្តសញ្ញាណប័ណ្ណប្រើប្រាស់គ្រប់ៗគ្នា។

អាជ្ញាធរសង្កាត់ បានសហការជាមួយកងកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ចុះល្បាតតាមគោលដៅសំខាន់ៗជារៀងរាល់ថ្ងៃដើម្បីគ្រប់គ្រងស្ថានភាពការណ៍ និងទប់ស្កាត់បទល្មើសផ្សេងដែលបម្រុងនឹងកើតមានឡើង ធានានូវសុវត្ថិភាពជូនបងប្អូនប្រជាពលរដ្ឋ។ លើសពីនេះជារៀងរាល់ខែ រដ្ឋបាលសង្កាត់បានរៀបចំវេទិការសាធារណៈជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដែលផ្តោតទៅលើការអនុវត្តន៍គោលនយោបាយភូមិ សង្កាត់មានសុវត្ថិភាព ដើម្បីដោះស្រាយបាននូវទុក្ខកង្វល់ ក៏ដូចជា សំណើរ សំណូមពរនានាជូនប្រជាពលរដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាសន្តិសុខក្នុងមូលដ្ឋានក៏នៅតែមិនទាន់បានល្អ ប្រសើរមួយរយភាគរយនៅឡើយទេ តែអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវបានយកចិត្តទុកដាក់យ៉ាងសកម្មបន្ថែមទៀតផងដែរ។ បញ្ហាមួយទៀតគឺ សណ្តាប់ធ្នាប់សាធារណៈ ការលក់ដូរ ការចតយានជំនិះលើចិញ្ចើមផ្លូវ បានធ្វើអោយគ្មានផ្លូវធ្វើដំណើរអ្នកថ្មើរជើង និងធ្វើអោយមានការកកស្ទះចរាចរណ៍ជារៀងរាល់ថ្ងៃ។ បច្ចុប្បន្ននេះរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ ក៏ដូចជារដ្ឋបាលសង្កាត់កំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងបំផុត ក្នុងការរំដោះចិញ្ចើមផ្លូវដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ និងចៀសវាងការកើតមានគ្រោះថ្នាក់ផ្សេងៗជាយថាហេតុដល់អ្នកដំណើរថ្មើរជើង។ ដូចនេះរដ្ឋបាលសង្កាត់បានរៀបចំផែនការ និងដាក់គោលដៅដើម្បីអនុវត្តដូចជា៖

- ផ្សព្វផ្សាយគោលនយោបាយភូមិ សង្កាត់មានសុវត្ថិភាព
- ពង្រឹងការអនុវត្តច្បាប់ចរាចរណ៍
- ពង្រឹងការរៀបចំសណ្តាប់ធ្នាប់សាធារណៈ
- ជម្រុញផ្តល់សៀវភៅស្នាក់នៅ
- ជម្រុញផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- ពង្រឹងផ្តល់សេវាសាធារណៈ។

## ៣.២ កម្មវិធីអភិវឌ្ឍន៍

### ៣.២.១ ក្របខ័ណ្ឌវិនិយោគ

ដើម្បីចូលរួមចំណែកអោយបានជោគជ័យ តាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ការចូលរួមចំណែកក្នុងបរិបទនេះ គឺជាកិច្ចការរបស់ក្រុមប្រឹក្សាសង្កាត់ និងគណៈកម្មាធិការកសាងផែនការ និងថវិកាសង្កាត់ធ្វើយ៉ាងណាកំណត់អោយបានច្បាស់លាស់អំពីក្របខណ្ឌនៃការវិនិយោគ។

ដោយមានតួនាទី និងភារកិច្ចជាអ្នកទទួលខុសត្រូវលើកិច្ចការអភិវឌ្ឍន៍សង្កាត់ គណៈកម្មាធិការ កសាងផែនការ និងថវិកាបានរៀបចំប្រជុំផ្សព្វផ្សាយពីដំណើរការកសាងកម្មវិធីវិនិយោគ ឆ្នាំ ២០១៩-២០២១ ព្រមទាំងមានការចូលរួមពីប្រជាពលរដ្ឋក្នុងការធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈ ជាពិសេសគឺការអនុវត្តន៍គោលនយោបាយជាតិធ្វើអោយមានកំណើនសេដ្ឋកិច្ច ដោយចីរភាពក្នុងការកាត់បន្ថយភាពក្រីក្រ។ ដើម្បីអោយជាក់ស្តែងពិតប្រាកដក្នុងការឈានដល់ទៅការសម្រេចបានខ្លឹមសារដូចខាងក្រោម៖

- ជួសជុល និងកែលម្អផ្លូវលំក្នុងមូលដ្ឋាន
- រៀបចំប្រព័ន្ធលូ និងស្តារប្រលាយរំដោះទឹកក្នុងភូមិ
- រៀបចំគាំទ្រវិស័យកសិកម្ម ផ្តល់ថ្នាំ និងវគ្គបណ្តុះបណ្តាលការងារកសិកម្ម
- ប្រជាពលរដ្ឋមានដើមទុនគ្រប់គ្រាន់ក្នុងការបង្កើតមុខរបរ
- ផ្តល់សេវាសុខាភិបាលអោយបានល្អ មានការថែទាំគាំទ្រ និងកម្មវិធីការពារជម្ងឺឆ្លងផ្សេងៗដល់ប្រជាជនដល់ស្ត្រី និងកុមារ
- ធ្វើអោយប្រជាជនមានការយល់ដឹង និងចូលរួមទុកដាក់សំរាមឲ្យបានត្រឹមត្រូវ
- មានបន្ទប់រៀនគ្រប់គ្រាន់សម្រាប់សិស្សសិក្សា
- កាត់បន្ថយ និងទប់ស្កាត់អំពើហឹង្សា
- ទប់ស្កាត់អោយបាននូវអំពើពេស្យា ការជួញដូរស្ត្រី និងកុមារ
- បង្កើនការជម្រុញទឹកចិត្តស្ត្រីអោយចូលរួមការអភិវឌ្ឍន៍មូលដ្ឋាន[24]

### ៣.២.២ ក្របខ័ណ្ឌផ្តល់សេវា

ក្របខ័ណ្ឌផ្តល់សេវារបស់សង្កាត់ចោមចៅទី២ មានគោលដៅផ្តល់នូវសេវាសាធារណៈ ដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានអោយបានគ្រប់គ្រាន់ទៅតាមតម្រូវការ។ ក្នុងន័យនេះ សង្កាត់ចោមចៅទី២បានដាក់នូវផែនការ ក៏ដូចជាយុត្តិសាស្ត្រជាច្រើនដើម្បីកែទម្រង់ផ្នែកសេវារដ្ឋបាលអោយមាន

[24] សៀវភៅផែនការអភិវឌ្ឍន៍៥ឆ្នាំសម្រាប់ឆ្នាំ២០១៨- ២០២២ របស់សង្កាត់ចោមចៅទី២ ,ទំព័រ២២

ភាពសុក្រឹត្យ និងធ្វើយ៉ាងណាអោយប្រជាពលរដ្ឋទទួលបានសេវានេះគ្រប់ៗគ្នា។ ក្របខ័ណ្ឌផ្តល់សេវាដែលសង្កាត់ចោមចៅទី២ ផ្តល់ជូនប្រជាពលរដ្ឋមានដូចតទៅ៖

- ផ្តល់អត្រានុកូលដ្ឋាន
- ផ្ទេរកម្មសិទ្ធដីធ្លី
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត
- លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ពោះម៉ាយ
- សំបុត្រមរណភាព
- ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍
- សំបុត្រអាពាហ៍ពិពាហ៍( ពលរដ្ឋខ្មែរ និងខ្មែរ, ខ្មែរ និងបរទេស
- លិខិតបញ្ជាក់ស្នាមមេដៃផ្សេងៗ
- លិខិតបញ្ជាក់ ជួលដី តូប ផ្ទះ និងយានជំនិះ

### ៣.២.៣ ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា

លិខិតបទដ្ឋានគតិយុត្តដែលត្រូវរៀបចំ និងការអនុវត្តន៍រយៈពេល៥ឆ្នាំ(២០១៨ - ២០២២) របស់រដ្ឋបាលសង្កាត់ចោមចៅទី២ មាន៖

- ដីការ ស្តីពីការបង្កើតបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាសង្កាត់
- សេចក្តីសម្រេច ស្តីពីការបង្កើត គ ផ ថ
- សេចក្តីសម្រេច ស្តីពីការបង្កើត គ ក ន ក
- សេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង
- សេចក្តីសម្រេចបង្កើតគណៈកម្មការ លទ្ធកម្ម
- សេចក្តីសម្រេច ស្តីពីការតែងតាំងជនបង្គោលតាមដាននិងត្រួតពិនិត្យនិងវាយតម្លៃ
- សេចក្តីសម្រេច ស្តីពីការតែងតាំងវេជ្ជទេយ្យករចំណូល
- សេចក្តីសម្រេច ស្តីពីការតែងតាំងវេជ្ជទេយ្យករបុរេប្រទាន
- សេចក្តីសម្រេច ស្តីពីការតែងតាំងភ្នាក់ងារបើកផ្តល់។

## ៣.៣ ការតាមដាន និងការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍[25]

ការតាមដាន និងការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានសង្កាត់ មានតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងគម្រោងផែនការ ក្នុងគោលបំណងរួមចំណែកអនុ

[25] សៀវភៅផែនការអភិវឌ្ឍន៍៥ឆ្នាំសម្រាប់ឆ្នាំ២០១៨- ២០២២ របស់សង្កាត់ចោមចៅទី២,ទំព័រ៣០

វត្តអោយបានត្រឹមត្រូវ និងមានការផ្លាស់ប្តូរលើចំណុចខ្វះខាតក្នុងការកសាងផែនការ និងការអនុវត្តជាក់ស្តែង។ ការត្រួតពិនិត្យ និងការវាយតម្លៃមានលក្ខណៈសំខាន់ណាស់ ដើម្បីបង្ហាញដល់អ្នកដឹកនាំ និងអ្នកដែលមានការពាក់ព័ន្ធទាំងអស់អំពី ប្រសិទ្ធភាពរបស់ផែនការអភិវឌ្ឍន៍ សំដៅអោយប្រសើរឡើងនូវគុណភាពនៃការអនុវត្តន៍ផែនការ និងការគ្រប់គ្រងគម្រោង។

ផែនការតាមដានការអនុវត្តផែនការអភិវឌ្ឍន៍មូលដ្ឋានសង្កាត់ នាំអោយមានការត្រួតពិនិត្យជាប្រចាំលើការរីកចម្រើន ដោយប្រៀបធៀបទៅនឹងផែនការ តាមរយៈការប្រមូលពត៌មានជាប្រចាំដើម្បីបង្ហាញពីលទ្ធផលដែលបានពីការអនុវត្តគម្រោងផែនការអភិវឌ្ឍន៍សង្កាត់។ កិច្ចសហការជាមួយជនបង្គោលតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីការអភិវឌ្ឍន៍មូលដ្ឋានអ្នកសម្របសម្រួល ការិយាល័យផែនការ និងអភិវឌ្ឍន៍ក្របខណ្ឌមន្ទីរ អង្គភាពនានា និងជនបង្គោលតាមដាន និងការវាយតម្លៃរបស់ក្រុមប្រឹក្សាសង្កាត់ ដើម្បីរៀបចំប្រតិទិនការងារ និងធ្វើការអនុវត្តន៍ និងធ្វើរបាយការណ៍ជាប្រចាំនៃការអនុវត្តន៍គម្រោងនានា នៅតាមមូលដ្ឋានក្នុងភូមិសង្កាត់។

សមិទ្ធផលនៃការងារនានាជាកិច្ចចាំបាច់ និងមានសារៈសំខាន់ពុំអាចរំលងបានសម្រាប់ការងារ គ្រប់គ្រងរបស់សង្កាត់។ ការតាមដាន និងការវាយតម្លៃគឺត្រូវធ្វើឡើងដើម្បីជំរុញឲ្យការងារអនុវត្តបាន ប្រព្រឹត្តទៅដល់គោលបំណងអភិវឌ្ឍន៍ ដែលបានកំណត់ហើយក៏ដើម្បីមានការសម្រេចចិត្ត (ផ្តល់ការលើកទឹកចិត្តឬកែតម្រូវជាចាំបាច់) ដូច្នេះក្នុងការតាមដាននិងវាយតម្លៃការសម្រេចចិត្តបាននៃក្របខ័ណ្ឌអភិវឌ្ឍន៍សង្កាត់សម្រាប់រយៈពេល៥ឆ្នាំះ

- **យន្តការតាមដាន និងវាយតម្លៃះ** ដើម្បីរៀបចំបង្កើតនូវយន្តការអោយបានសមស្របតាមគោលការណ៍ និងមានប្រសិទ្ធភាពក្នុងការតាមដាន និងវាយតម្លៃអោយបានស៊ីជម្រៅទៅលើផលប៉ះពាល់ទាំងឡាយនៃផែនការអភិវឌ្ឍន៍សង្កាត់ ដោយមានការទទួលខុសត្រូវខ្ពស់ព្រមទាំងមានការចូលរួមពីដៃគូរអភិវឌ្ឍន៍នានា សំដៅធានាអោយមានប្រសិទ្ធភាព និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

  ក្រុមប្រឹក្សាចៅសង្កាត់ នឹងអ្នកពាក់ព័ន្ធនានា រៀបចំយន្តការតួនាទីភារកិច្ច និងការទទួលខុសត្រូវសម្រាប់ធ្វើការតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍៥ឆ្នាំ(២០១៨-២០២២) និងធ្វើការបូកសរុបរបាយការណ៍រាល់ដំណាច់ឆ្នាំនីមួយៗ ក្នុងនោះដែលសង្កាត់ត្រូវអនុវត្តការតាមដានអោយបានទៀងទាត់ ព្រមទាំងការចុះជាក់ស្តែងដល់ទីតាំងអភិវឌ្ឍន៍គម្រោង។

ក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលខុសត្រូវក្នុងការតាមដាន និងវាយតម្លៃរៀងរាល់ឆ្នាំលើការអនុវត្តន៍ផែនការអភិវឌ្ឍន៍ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សា ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតដូចជាក្រសួង ស្ថាប័ន អង្គការនានារបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ។

- **វិធីសាស្ត្រតាមដាន និងការវាយតម្លៃ៖** រៀបចំអោយជនបង្គោល ឬគណៈកម្មាធិការ កសាងផែនការ និងថវិកាសង្កាត់ត្រូវត្រួតពិនិត្យនឹងវាយតម្លៃជាប្រចាំ ពីការរីកចម្រើនធៀបនឹងផែនការអនុវត្តន៍ដែលបានលើកឡើង ការចុះតាមដានក្នុងដំណាក់ការអនុវត្តន៍គម្រោង ហើយធានាបានថាការរីកចម្រើនត្រូវបានប្រមូល និងផ្តល់របាយការណ៍អំពីការរីកចម្រើន និងបញ្ហាដែលជួបប្រទះដែលកើតមានឡើងដល់ក្រុមប្រឹក្សាសង្កាត់ ឬចៅសង្កាត់ដើម្បីជួយដោះស្រាយ ចូលរួមផ្តល់អនុសាសន៍កែលម្អ និងផ្តល់ការសម្រេចចិត្តលើគម្រោងផែនការដែលបានគ្រោងទុក។ ហើយវិធីសាស្ត្រនៃការវាយតម្លៃសម្រេចបាននូវគោលដៅគោលបំណង និងចក្ខុវិស័យ អភិវឌ្ឍន៍នៃផែនការ៥ឆ្នាំរបស់សង្កាត់ចោមចៅទី២។
- **សូចនាករតាមដាន និងវាយតម្លៃ៖** សូចនាករដែលបានកើតមានឡើង តារាងក្របខ័ណ្ឌអភិវឌ្ឍន៍នៃកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានត្រូវប្រជុំឆ្លុះបញ្ចាំងនូវពត៌មានត្រឡប់ ដល់ភ្នាក់ងារអនុវត្តគម្រោងដើម្បីអោយប្រសើរឡើងនូវការតម្រង់ទិសនៃការអនុវត្តន៍ផែនការ អោយបានស្របនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ដែលបានលើកឡើងក្នុងការអភិវឌ្ឍន៍ ៥ឆ្នាំ ហើយនៅចុងអាណត្តិរបស់ក្រុមប្រឹក្សាសង្កាត់ត្រូវមានការវាយតម្លៃពីលទ្ធផល សមិទ្ធផល នៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលសង្កាត់តាមសេចក្តីណែនាំរបស់ គ.ជ.អ.ប[26] សម្រាប់ប្រើប្រាស់ជាខ្នាត់ដើម្បីវាស់វែងអំពីការអភិវឌ្ឍនៈភាពនៃផែនការអភិវឌ្ឍន៍។

[26] គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សេចក្ដីសន្និដ្ឋាន

សរុបសេចកម្ដីកដោយយោងទៅតាមការបកស្រាយខាងលើយើងអាចធ្វើការសន្និដ្ឋាន បានថា **ការរៀបចំ និងការប្រព្រឹត្តទៅរបស់សង្កាត់ចោមចៅទី២** ពិតជាមានការល្អប្រសើរនឹងពិតជាបានអនុលោមតាមគោលការណ៍នៃច្បាប់ដែលពាក់ព័ន្ធនានា។ ការគ្រប់គ្រងរដ្ឋបាលសង្កាត់ចោមចៅទី២ គឺជា ទម្រង់នៃការអនុវត្តសេវាសាធារណៈ និងដោះស្រាយបញ្ហាក្នុងមូលដ្ឋានជូនប្រជាពលរដ្ឋ។

លំហូរនៃការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល បាននឹងកំពុងបញ្ជាក់យ៉ាងច្បាស់ថា ការគ្រប់គ្រងរដ្ឋបាលនៅកម្ពុជាគឺបានផ្ដោតសំខាន់ណាស់ ចាត់តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ ជាពិសេសគឺថ្នាក់មូលដ្ឋានឃុំ សង្កាត់។ នេះសមបញ្ជាក់អោយឃើញថាកម្ពុជាកំពុងប្រកាន់យករបបនៃការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ ដែលស្ថិតនៅជិតនឹងប្រជាពលរដ្ឋ ហើយងាយស្រួលក្នុងការដឹងសុខទុក្ខរាស្ត្រថ្នាក់ក្រោមជាតិ។ ឃុំ សង្កាត់ជារដ្ឋបាលថ្នាក់មូលដ្ឋានមួយមានសារសំខាន់ណាស់របស់រាជរដ្ឋាភិបាលដើម្បីធ្វើការពង្រឹងមូលដ្ឋាន និងដើម្បីងាយស្រួលក្នុងការអភិវឌ្ឍន៍អោយចំទៅនឹងគោលដៅដែលប្រជាពលរដ្ឋត្រូវការ មិនត្រឹមតែប៉ុណ្ណោះវាមាននាទីក្នុងការចុះរៀបចំហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ រៀបចំប្រព័ន្ធធារាសាស្ត្រ ទូរគមនាគមន៍ សន្តិសុខ មណ្ឌលសុខ ភាព និងផ្ដល់ពត៌មានជូនប្រជាពលរដ្ឋទាន់ពេលវេល-ល-។

ការគ្រប់គ្រងរដ្ឋបាលរបស់សង្កាត់ចោមចៅទី២ សមាសភាពក្រុមប្រឹក្សានីមួយៗសុទ្ធតែបានបង្កើតឡើងតាមរយៈឆន្ទៈ របស់ប្រជាពលរដ្ឋនៅមូលដ្ឋានសង្កាត់ផ្ទាល់ ពោលគឺការបោះឆ្នោតជាសកលដោយសេរី យុត្តិធម៌ ដោយសេរីភាព ដោយចំពោះ និងដោយសំងាត់។

ជារួមមកដោយមានការខិតខំប្រឹងប្រែងរបស់មន្ត្រីក្នុងសាលាសង្កាត់ចោមចៅទី២ បានធ្វើអោយក្នុងមូលដ្ឋានសង្កាត់មានការរីកចម្រើនជាលំដាប់រួមមាន សំណង់អាគារតូចធំ មន្ទីរពេទ្យ សាលារៀនរដ្ឋនឹងឯកជន ផ្លូវបេតុង និងមានប្រព័ន្ធសេដ្ឋកិច្ចដំណើរការយ៉ាងល្អប្រសើរ-ល- ព្រមទាំងមានការសហការនឹងចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋទៀតនោះបានធ្វើអោយ សង្កាត់ចោមចៅទី២ក្លាយជាសង្កាត់ដ៏គំរូមួយ និងមានរបៀបរៀបរយលើការផ្ដល់សេវាសាធារណៈ សណ្ដាប់ធ្នាប់ទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធរដ្ឋបាលផ្សេងៗនៅក្នុងមូលដ្ឋានខណ្ឌពោធិ៍សែនជ័យ។

ក្របខ័ណ្ឌនៃការផ្ដល់សេវារបស់សង្កាត់ចោមចៅទី២ គឺមានគោលដៅក្នុងការផ្ដល់នូវសេវាសាធារណៈដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន អោយបានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ។ ជាពិសេសក្រុមប្រឹក្សាសង្កាត់ក៏មានទិសដៅរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនដោយមានវិធានដូចជា ការវាយតម្លៃអាទិភាព និងសកម្មភាពអភិវឌ្ឍន៍ ប្រមូលផ្ដុំសេចក្ដីត្រូវការនានារួចកំណត់អំពីអាទិភាពនៃសេចក្ដីត្រូវការអោយបានជាក់លាក់ ដោយផ្អែកលើធនធាន គម្រោងថវិកា និងថវិកាដែលឃុំមាន។

# អនុសាសន៍

បើតាមការស្រាវជ្រាវ និងការជួបប្រទះជាក់ស្តែង ចំពោះការអនុវត្តន៍នូវការគ្រប់គ្រងរដ្ឋបាលរបស់ឃុំ សង្កាត់ យើងខ្ញុំយល់ឃើញថាវាមានភាពល្អប្រសើរ ព្រមទាំងមានការអភិវឌ្ឍន៍។ ប៉ុន្តែទោះជាយ៉ាងណាចំណុចខ្វះខាតក៏នៅមានច្រើនផងដែរ ចំណុចទាំងនោះវាសបញ្ជាក់អោយឃើញថាសង្កាត់ចោមចៅទី២ ត្រូវការការរួមសហការពីប្រជាពលរដ្ឋក្នុងមូលដ្ឋានបន្ថែមការអភិវឌ្ឍន៍ និងការជួយជ្រោមជ្រែងពីសំណាក់រាជរដ្ឋាភិបាលបន្ថែមទៀត ដោយនៅមើលឃើញថាការផ្តល់សេវាសាធារណៈនៅមានចន្លោះ ក៏ដូចជាការងារមួយចំនួនទៀត ដែលរាជរដ្ឋាភិបាលគួរតែយកចិត្តទុកដាក់អោយកាន់តែប្រសើររាជរដ្ឋាភិបាលគួរតែះ

- រៀបចំហេដ្ឋារចនាសម្ព័ន្ធ រូបវន្ត និងទីតាំងជូនដល់សង្កាត់ចោមចៅទី២ឲ្យកាន់តែប្រសើរឡើងព្រោះទីនោះពុំទាន់មានទីតាំងរបស់ខ្លួនឯងនៅឡើយទេ ពោលគឺទីតាំងសព្វថ្ងៃសាលាសង្កាត់ ត្រូវបានជួលផ្ទះ ចំនួន២ល្វែង ដើម្បីធ្វើការងារផ្តល់សេវាក្នុងមូលដ្ឋានរបស់ខ្លួន។
- រៀបចំបើកវគ្គបណ្តុះបណ្តាលមន្ត្រីក្រមខណ្ឌ និងមន្ត្រីកិច្ចសន្យាក្នុងមូលដ្ឋានឃុំ សង្កាត់ ដើម្បីពង្រឹងនូវសមត្ថភាព ការងារមន្ត្រី ក្រមសីលធម៌មន្ត្រី ដោះស្រាយទំនាស់ជូនប្រជាពលរដ្ឋ សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល វិជ្ជាជីវៈមន្ត្រី ពត៌មានវិជ្ជា បន្ថែមទៀតអោយកាន់តែប្រសើរ និងជាពិសេសគឺផ្នែកបច្ចេកទេស។
- បង្កើនថវិកាក្នុងការអភិវឌ្ឍន៍ឃុំ សង្កាត់អោយស្របតាមតម្រូវការ និងចំនួននៃការកើនឡើងរបស់ប្រជាពលរដ្ឋ ជាពិសេសគឺតំបន់មូលដ្ឋានដែលមានភាពក្រីក្រលំបាក តំបន់ដាច់ស្រយាល និងព្រំដែនជាដើម។
- បង្កើនចំនួនធនធានមនុស្សឲ្យក្លាយទៅជាមន្ត្រីដែលមានសមត្ថភាព ក្នុងឃុំ សង្កាត់ ដើម្បីឲ្យស្របទៅនឹងចំនួនប្រជាពលរដ្ឋ និងទំហំនៃសមត្ថកិច្ចដែនដីក្នុងមូលដ្ឋាន ដើម្បីអោយការផ្តល់សេវា ការងារ និងការដោះស្រាយវិវាទមានប្រសិទ្ធភាព និងមានភាពឆាប់រហ័ស។
- ក្រុមប្រឹក្សាឃុំ សង្កាត់គួរតែត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់បុគ្គលិកឃុំ សង្កាត់អំពីការប្រើប្រាស់ឥរិយាបថលើប្រជាពលរដ្ឋ ថាតើពួកគាត់បានបំពេញក្រមសីលធម៌ជាមន្ត្រីបានសមគួរដែរឬទេ នៅពេលបំពេញការងារ ក៏ដូចជាពេលដែលប្រជាពលរដ្ឋ មកទទួលសេវា រឺសាកសួរពត៌មាន។

# គន្ថនិទ្ទេស

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០០៦។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១។

អនុក្រឹត្យលេខ ១៦ អនក្រ/បក ស្តីពីមូលនិធិឃុំ សង្កាត់ឆ្នាំ២០០២។

អនុក្រឹត្យលេខ ២២ អនក្រ/បក ស្តីពីការផ្ទេរសិទ្ធិការអំណាច តួនាទី និងភារកិច្ចទៅអោយ ក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០០២។

អនុក្រឹត្យលេខ ២៦ អនក្រ/បក ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ឆ្នាំ២០០២។

## សៀវភៅ

ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់តាមបែបវិមជ្ឈការរបស់ក្រសួងមហាផ្ទៃឆ្នាំ ២០១៧។

នីតិរដ្ឋបាលទូទៅ របស់អនុបណ្ឌិត ហៀង សាង ឆ្នាំ២០១១។

កម្មវិធីវិនិយោគរំកិល៣ឆ្នាំរបស់សង្កាត់ចោមចៅទី២។

ផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់សង្កាត់ចោមចៅទី២។

## ឯកសារផ្សេងៗ

ឯកសារបានពីការសំភាសន៍ចៅសង្កាត់ចោមចៅទី២។

ឯកសារស្វែងរកតាមប្រព័ន្ធអ៊ីនធើណេត។

ឯកសារពីសៀវភៅរដ្ឋបាលផ្សេងៗ។

# ច្បាប់

## ស្តីពី

## ការគ្រប់គ្រងរដ្ឋបាល
## ឃុំ សង្កាត់

នស / រកម / ០៣០១ / ០៥

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤នៃរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និង ពីសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤១/ ០០៣ / ២០០១ កបធ.ច ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖ ។ល។

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាតាមនយោបាយវិមជ្ឈការ ។

**មាត្រា ២.-**

ឃុំ សង្កាត់ជានីតិបុគ្គល ។

**មាត្រា ៣.-**

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។

**មាត្រា ៤.-**

អំណាចដឹកនាំនិងគ្រប់គ្រងឃុំ សង្កាត់បានមកដោយការបោះឆ្នោតជាទូទៅជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ក្នុងក្របខ័ណ្ឌនៃឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៥.-**

ឃុំ សង្កាត់គ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួនដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

អំណាចបញ្ញត្តិ អំណាចប្រតិបត្តិក្នុងការគ្រប់គ្រងមូលដ្ឋានត្រូវផ្តល់ឱ្យឃុំ សង្កាត់ ហើយអំណាចនេះត្រូវអនុវត្តស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវសំរេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលមានការប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ត្រូវរ៉ោ.

សម្រេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

កាលបើមានផលវិបាកណាមួយកើតឡើង ក្រោយពេលដែលឃុំ សង្កាត់ ត្រូវបានបង្កើត លុបចោលឬកែសម្រួល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសដើម្បីដោះស្រាយផលវិបាកនោះស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៨.-**

ឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានដោយករណីប្រធានសក្តិ រាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា។

បន្ទាប់ពីបានរាយការណ៍ជូនរដ្ឋសភារួចហើយ រាជរដ្ឋាភិបាលត្រូវចាត់ឱ្យក្រសួងមហាផ្ទៃរៀបចំគ្រប់គ្រងឃុំ សង្កាត់ទាំងនោះជាបណ្តោះអាសន្ន ហើយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះនឹងត្រូវដំណើរការ នៅពេលស្ថានការណ៍ឃុំ សង្កាត់ទាំងនេះមានប្រក្រតីភាពឡើងវិញ ។

## ជំពូកទី ២
## ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៩.-**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបំពីផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។៚

**មាត្រា ១១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង ។

ក្នុងតំណាក់កាលអន្តរកាលនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលផុតអាណត្តិមានភារកិច្ចសំរួលកិច្ចការប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកចំនួនពី ៥ ទៅ ១១រូប ផ្អែកតាមប្រជាសាស្ត្រនិងភូមិសាស្ត្ររបស់ខ្លួន ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាតាមឃុំ សង្កាត់នីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានកំណត់រួចហើយ អាចធ្វើការផ្លាស់ប្តូរបានដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យដោយការផ្លាស់ប្តូរនៃប្រជាសាស្ត្រនិងភូមិសាស្ត្រ ។

សមាជិកបន្ថែមនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសតាមនីតិវិធីដូចសមាជិកដទៃទៀតដែរ ។

**មាត្រា ១៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានម្នាក់ហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ច :

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាននិងបទបញ្ញាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់និងបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ
- រក្សារបៀបរៀបរយនិងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ ។ល។

**មាត្រា ១៤.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិនិងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញល័ក្ខខ័ណ្ឌសំខាន់ៗដូចខាងក្រោម :

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាននិងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ១៥.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ។

**មាត្រា ១៦.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៤នៃច្បាប់នេះ ។

- ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ
- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាព ត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

**មាត្រា ១៧.-**

ត្រូវរៀបចំធ្វើការបោះឆ្នោតឡើងវិញក្នុងរយៈពេល ១២០ថ្ងៃយ៉ាងយូរ ដើម្បីធ្វើការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីណាមួយដូចខាងក្រោម :

- ឃុំ សង្កាត់ដែលបង្កើតថ្មីតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយចោលតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៥៧ និងមាត្រា ៥៨ នៃច្បាប់នេះ ។

ការបោះឆ្នោតឡើងវិញដូចមានចែងខាងលើនេះត្រូវចាត់ចែងធ្វើឡើង អនុលោមទៅតាមបែបបទនិងនីតិវិធីដែលបានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពី ១៨០ថ្ងៃ ។

ក្នុងរយៈពេលនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវតែងតាំងសមាសភាពនិងកំណត់អំពីសមត្ថកិច្ច របៀបរបបដឹកនាំគ្រប់គ្រងឃុំ សង្កាត់នោះ រហូតដល់មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

**មាត្រា ១៨.-**

ការកែប្រែព្រំប្រទល់របស់ឃុំ សង្កាត់ណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការកែប្រែនោះ ពុំបណ្តាលឱ្យផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ។/.

ការបង្កើតឃុំ សង្កាត់ថ្មីណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការបង្កើតនោះពុំបណ្តាលឱ្យមានផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សានៃឃុំ សង្កាត់ដែលពាក់ព័ន្ធ ។

ក្នុងករណីឃុំ សង្កាត់ដែលត្រូវបង្កើតថ្មី ដែលត្រូវលុបចោល ដែលត្រូវកែប្រែព្រំប្រទល់ ហើយបណ្តាលឱ្យមានការផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ត្រូវចូលជាធរមានសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាអាណត្តិបន្ទាប់ ។

**មាត្រា ១៩.-**

ក្នុងអំឡុងពេល ១៤ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ត្រូវចាត់ឱ្យមានការប្រជុំជាលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រង ។

**មាត្រា ២០.-**

មុនចាប់ផ្តើមការងារ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំនិងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសំរាប់អង្គប្រជុំនិងរបៀបរបបធ្វើការងាររបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីគោលការណ៍នានាសំរាប់ជាមូលដ្ឋានដល់ការរៀបចំបទបញ្ជាផ្ទៃក្នុងខាងលើនេះ ។

**មាត្រា ២១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីប្រជុំ ។ល។

មាត្រា ២២.-

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ នឹងយកជាការបាន លុះត្រាតែមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួម ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ដើម្បីសំរេចបញ្ហាណាមួយដូចខាងក្រោម :

- អនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- អនុម័តលើគំរោងថវិកាឃុំ សង្កាត់
- កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាននិងកំរៃសេវាផ្សេងៗ
- អនុម័តបទបញ្ញាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងពេលអនុម័ត ប្រសិនបើមានសំឡេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព ។

មាត្រា ២៣.-

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើជាសាធារណៈនិងមានលក្ខណៈប្រជាធិបតេយ្យ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីរបៀបរបបប្រជុំខាងលើនេះ ។

មាត្រា ២៤.-

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានឡើយ ។ល។

## ជំពូកទី ៣
## រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

**មាត្រា ២៥.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ ។

**មាត្រា ២៦.-**

មេឃុំ ចៅសង្កាត់មានអ្នកជំនួយការដូចខាងក្រោម :

ចំពោះមេឃុំ អ្នកជំនួយការមានពីររូប :

-ជំទប់ទី ១ មួយរូប

-ជំទប់ទី ២ មួយរូប ។

ចំពោះចៅសង្កាត់ អ្នកជំនួយការមានពីររូប :

-ចៅសង្កាត់រងទី ១ មួយរូប

-ចៅសង្កាត់រងទី ២ មួយរូប ។

**មាត្រា ២៧.-**

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន ។

**មាត្រា ២៨.-**

ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបធ្វើជាស្មៀនឃុំ សង្កាត់ ។

ស្មៀនឃុំ សង្កាត់តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំ សង្កាត់ និងធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់ ។ល។

ស្មៀនឃុំ សង្កាត់ត្រូវផ្លាស់ប្តូរក្នុងករណីមានសំណើរបស់មេឃុំ ចៅសង្កាត់ អនុលោមតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២៩.-**

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួន តាមសេចក្តីត្រូវការនិងការចាំបាច់នៃការងារនិងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់ ។

**មាត្រា ៣០.-**

ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សំរាប់ភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន ។

មេភូមិត្រូវរៀបចំចាត់តាំងឱ្យមានអនុប្រធានមួយរូបនិងសមាជិកមួយរូបជាជំនួយការ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិនិងការតែងតាំងជំនួយការមេភូមិ ។

**មាត្រា ៣១.-**

មេភូមិមានភារកិច្ច :

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់ឱ្យដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែងនិងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំបន្ថែមអំពីរបៀបរបបធ្វើការងារនិងភារកិច្ចរបស់ភូមិ ឱ្យបានសមស្រប ។៚

**មាត្រា ៣២.-**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសចេញពីបេក្ខ-ជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានអាណត្តិស្មើនឹងអាណត្តិរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣៣.-**

ជំទប់ទី ១ ចៅសង្កាត់រងទី ១ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ២ ។

ជំទប់ទី ២ ចៅសង្កាត់រងទី ២ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ៣ ។

**មាត្រា ៣៤.-**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈទាំងអស់ក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។

**មាត្រា ៣៥.-**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែពីរដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាជាបេក្ខជន ដែលមានឈ្មោះលេខរៀងបន្ទាប់ពីបេក្ខជនដែលមានឈ្មោះលេខរៀងលំដាប់លើគេបង្អស់នៃបញ្ជីដែលបានទទួលសម្លេងឆ្នោតគាំទ្រលំដាប់ទីមួយ ឱ្យទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ និងជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះលេខរៀងលើគេបង្អស់ នៃបញ្ជីដែលបានទទួលសម្លេងគាំទ្រលំដាប់ទី ២ ឱ្យទទួលតំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។ល។

**មាត្រា ៣៦.-**

តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវបាត់បង់ក្នុងករណីសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។

**មាត្រា ៣៧.-**

មុខតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មុខតំណែងមេឃុំ ចៅសង្កាត់និងមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កាលបើមុខតំណែងណាមួយត្រូវបាត់បង់ មុខតំណែងទាំងអស់ខាងលើរបស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៅក្នុងបញ្ជីរួមជាមួយអតីតប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ ដែលបានបាត់បង់ពីមុខតំណែងនោះ ឱ្យទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់និងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មី ជំនួសកន្លែងដែលទំនេរតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីដែលបញ្ជីបេក្ខជនត្រូវកាន់កាប់តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់អស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចេញពីក្នុងបញ្ជីបេក្ខជនជាមួយ ផ្សេងៗតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦ នៃច្បាប់នេះនិងចាត់ឱ្យសមាជិកក្រុមប្រឹក្សារូបនេះទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ជំនួសប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ការបាត់បង់ពីមុខតំណែងនិងការទទួលតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៨.-**

តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបាត់បង់ពីមុខតំណែង ក្នុងករណីដែលសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សា ឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។ល។

ក្នុងករណីតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបានបាត់បង់ មុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៃបញ្ជីបេក្ខជនរួមជាមួយជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ឱ្យទទួលតំណែងជំនួសជំទប់ ឬចៅសង្កាត់រងដែលបានបាត់បង់ពីមុខតំណែងនិងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីជំនួសកន្លែងដែលទំនេរ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីបញ្ជីបេក្ខជនដែលត្រូវកាន់កាប់តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ អស់សមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសបេក្ខជនពីក្នុងបញ្ជីនោះបញ្ចូលជាសមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ នឹងប្រគល់ឱ្យសមាជិកក្រុមប្រឹក្សារូបនោះទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ជំនួសតំណែងជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះនិងល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ការបាត់បង់មុខតំណែងនិងការទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី២ ឬចៅសង្កាត់រងទី ២ ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៩.-**

មេឃុំ ចៅសង្កាត់បំពេញតួនាទីភារកិច្ចដូចខាងក្រោម :

- អនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តនូវបទប្បញ្ញត្តិនិងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនយ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ផ្តល់យោបល់ផ្សេងៗនិងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុនិងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុម /ស.

ប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឱ្យ ។

**មាត្រា ៤០.-**

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ច ដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យនិងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រង នៅពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន ។

ជំទប់ ឬចៅសង្កាត់រង ត្រូវធ្វើការបែងចែកភារកិច្ចដូចខាងក្រោម :

ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្តាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាងលើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ។

## ជំពូកទី ៤

## តួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

**មាត្រា ៤១.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចិរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

**មាត្រា ៤២.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ :

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ។
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។ល។

មាត្រា ៤៣.-

ក្នុងតួនាទីបំរើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជា-ពលរដ្ឋ ។

**មាត្រា ៤៤.-**

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សំរាប់អនុវត្ត ។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ។

**មាត្រា ៤៥.-**

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម :

- ព្រៃឈើ
- ប្រៃសណីយ៍និងទូរគមនាគមន៍
- ការពារប្រទេស ល.។.

- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

**មាត្រា ៤៦.-**

តួនាទី មុខងារនិងអំណាចរបស់ឃុំ សង្កាត់ ដូចមានចែងក្នុងមាត្រា ៤២, ៤៣ និងមាត្រា ៤៤នៃច្បាប់នេះ អនុវត្តបានតែក្នុងរង្វង់ដែនដីឃុំ សង្កាត់របស់ខ្លួនតែប៉ុណ្ណោះ ។

ក្នុងករណីមានបញ្ហាកើតឡើងទាក់ទងសមត្ថកិច្ចរវាងឃុំ សង្កាត់ពីរឬច្រើន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់ការឱ្យមានការសំរុះសំរួលគ្នារវាងរដ្ឋបាលដែលពាក់ព័ន្ធទាំងនោះ ។

**មាត្រា ៤៧.-**

តួនាទី មុខងារនិងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ដូចមានចែងក្នុងមាត្រា ៤២, ៤៣, ៤៤ និងមាត្រា ៤៥នៃច្បាប់នេះ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀតដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ឃុំ សង្កាត់មានអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ។

អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់សំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារនិងអំណាចរបស់ខ្លួន ។

ដីកាឃុំ សង្កាត់ត្រូវធ្វើឡើងតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ។

រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនិងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួននូវដីកាដែលបានសំរេចរួចហើយ ។ររ.

Bo Sw

មាត្រា ៤៩.-

ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ ។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ ។

ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំ សង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធត្រូវចាត់ទុកជាមោឃៈដាច់ខាត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងអំពីមោឃភាពនេះជាលាយលក្ខណ៍អក្សរដល់ឃុំ សង្កាត់សាមីនិងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

មាត្រា ៥០.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំអំពីទំរង់និងបែបបទ ដើម្បីឱ្យឃុំ សង្កាត់រៀបចំដីកាស្របទៅតាមសភាពការណ៍ក្នុងឃុំ សង្កាត់របស់ខ្លួន ។

មាត្រា ៥១.-

ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់តាមសេចក្ដីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែបញ្ហាទាំងឡាយដូចខាងក្រោម :

- ការអនុម័តលើគំរោងថវិកាឃុំ សង្កាត់
- ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកំរៃសេវាផ្សេងៗ
- ការបោះឆ្នោតអនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- ការអនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- បញ្ហាដទៃទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មេឃុំ ចៅសង្កាត់ដែលត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើប្រតិភូកម្មអំណាចឱ្យពុំអាចផ្ទេរអំណាចនេះបន្តទៅឱ្យបុគ្គលដទៃទៀតបានឡើយ ។ ៚

មាត្រា ៥២.-

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់ នៅតែទទួលខុសត្រូវលើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ ។

ការដកហូតនូវអំណាចដែលបានធ្វើប្រតិភូកម្ម មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការដែលបានធ្វើរួចហើយនោះទេឡើយ ។

## ជំពូកទី ៥
## ការតាមដាន ការត្រួតពិនិត្យនិងការធ្វើអន្តរាគមន៍

មាត្រា ៥៣.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់ពីនីតិវិធីផ្សេងៗសំរាប់ធ្វើការតាមដាននិងត្រួតពិនិត្យអំពីសកម្មភាពទូទៅរបស់ឃុំ សង្កាត់ដើម្បី :

- ពិនិត្យមើលអំពីនីត្យានុកូលភាពនៃការគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទី ភារកិច្ច របស់ឃុំ សង្កាត់នីមួយៗ
- ពិនិត្យមើលការវិវត្តន៍អំពីសមត្ថភាពរបស់ឃុំ សង្កាត់នានា
- ប៉ាន់ប្រមាណអំពីការធ្វើអន្តរាគមន៍និងការជួយឧបត្ថម្ភគាំទ្រចំពោះឃុំ សង្កាត់ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទីភារកិច្ច ។

ក្នុងការតាមដាន ការត្រួតពិនិត្យនិងការធ្វើការអន្តរាគមន៍ចំពោះឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចបំបែកអំណាចដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឱ្យជួយកិច្ចការនេះទៅតាមសំណូមពរការងារ ។

មាត្រា ៥៤.-

ឃុំ សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឱ្យមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់ ។ល។

ភារកិច្ចដែលច្បាប់បានតម្រូវ គឺជាភារកិច្ចមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ មានកាតព្វកិច្ចបំពេញតាមល័ក្ខខ័ណ្ឌទាំងឡាយនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានពាក់ព័ន្ធ ឬបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់ ។

**មាត្រា ៥៥.-**

ការតាមដាន ត្រួតពិនិត្យនិងធ្វើអន្តរាគមន៍រួមមានការងារ :

- ស៊ើបអង្កេតនិងវាយតំលៃ
- ធ្វើសេចក្តីណែនាំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញភារកិច្ចដែលច្បាប់បានតម្រូវ
- ធ្វើជំនួសក្នុងការបន្តបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ។

**មាត្រា ៥៦.-**

ការធ្វើអន្តរាគមន៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥៤ នៃច្បាប់នេះត្រូវមានលក្ខណៈសមហេតុផលនិងស្របទៅតាមទំហំនៃកិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ដោយភ្ជាប់ជាមួយនូវការណែនាំនិងការគាំទ្រសំខាន់ចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចបំពេញភារកិច្ចដែលច្បាប់បានតំរូវជាធម្មតា ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គល ឬអង្គការណាមួយ ឬធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌឱ្យបំពេញការងារចាំបាច់ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមខ្លួនចំពោះកិច្ចការណាមួយ ។

**មាត្រា ៥៧.-**

កាលបើការធ្វើអន្តរាគមន៍មិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បានតម្រូវណាមួយ ឬមួយចំនួនក្នុងអំឡុងពេល ៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់ក៏មិនអាចបំពេញបាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយធ្វើការបោះឆ្នោតឡើងវិញទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ ល.ក.

មាត្រា ៥៨.-

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ណាធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ផ្ទុយនឹងនយោបាយរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ នោះជាបន្ទាន់ ហើយត្រូវធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះឡើងវិញ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

មាត្រា ៥៩.-

ត្រូវបង្កើតឱ្យមានអង្គភាពមួយចំណុះក្រសួងមហាផ្ទៃដើម្បីធ្វើជាសេនាធិការអំពីការងាររដ្ឋបាលមូលដ្ឋាន ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៦
## ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

មាត្រា ៦០.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័តនិងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំសង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធីនិងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

មាត្រា ៦១.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់ជាតិ ។

មាត្រា ៦២.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំទី ១ នៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវពិនិត្យឡើងវិញដើម្បីផ្តល់ទិន្នន័យថ្មីៗជារៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។ ល.ត.

**មាត្រា ៦៣.-**

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅ :

- វាយតំលៃអំពីកំរិតអត្ថិភាពនៃការអភិវឌ្ឍន៍និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន

- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះ ដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់មាននិងធនធានដែលបានទទួល

- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវានិងការអភិវឌ្ឍន៍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់

- ផ្តល់សេវានិងការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន

- ពិនិត្យ តាមដាននិងវាយតំលៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍

- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតំលៃអំពីកំរិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន

- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ជូនប្រជាពលរដ្ឋរបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦៤.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិនិងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង ។

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រនិងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល ។ ៖ ៖

**មាត្រា ៦៤.-**

ក្នុងករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់នេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់កែតម្រូវផែនការរបស់ខ្លួនឱ្យបានសមស្របក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលច្បាប់ចម្លងនៃផែនការនោះ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសំរួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦៦.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យនិងវាយតំលៃរាល់ការអនុវត្តផែនការ កម្មវិធី គំរោងនិងការផ្តល់សេវានានាប្រកបដោយតម្លាភាពនិងមានការទទួលខុសត្រូវខ្ពស់ ។

**មាត្រា ៦៧.-**

ក្រុមប្រឹក្សាឃុំ សង្កាត់នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យនិងការវាយតំលៃចំពោះផែនការ កម្មវិធីនិងគំរោងនានា ទោះជាការងារនោះត្រូវបានអនុវត្តដោយសមាសភាពណាក៏ដោយដែលខ្លួនបានជ្រើសយក ។

**មាត្រា ៦៨.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំក្រុមប្រឹក្សាឃុំ សង្កាត់អំពីវិធីផ្សេងៗក្នុងការអនុវត្តផែនការនិងក្នុងការត្រួតពិនិត្យ វាយតំលៃចំពោះការប្រើប្រាស់មូលនិធិសំរាប់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៦៩.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំអំពី :

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ទាឆ្នាំសារពើពន្ធកន្លងមក
- លទ្ធផលនៃការអនុវត្តចំពោះកិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍ទាំងនោះរបស់ឃុំ សង្កាត់ ။ល។

- វិធានការធ្វើឱ្យបានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តសេចក្តីរាយការណ៍នេះក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីបំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។

**មាត្រា ៧០.-**

សេចក្តីរាយការណ៍ប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា ៦៩នៃច្បាប់នេះ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- ចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តម្កល់ទុកជាសាធារណៈ
- ចម្លងចែកជូនអង្គការ សមាគមនិងសាធារណជនសំខាន់ៗដោយគិតត្រឹមថ្លៃដើម ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យពិចារណាទៅលើមតិយោបល់ផ្សេងៗដែលបានផ្តល់ចំពោះសេចក្តីរាយការណ៍ដូចមានចែងក្នុងមាត្រា ៦៩ និងមាត្រា ៧០នៃច្បាប់នេះ ហើយត្រូវទទួលយកនូវមតិយោបល់ល្អៗ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៧២.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវពិគ្រោះពិភាក្សាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងនូវបទប្បញ្ញត្តិនានា ដែលបានចែងក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

## ជំពូកទី ៧
## ហិរញ្ញវត្ថុឃុំ សង្កាត់

**មាត្រា ៧៣.-**

ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកានិងទ្រព្យសម្បត្តិផ្ទាល់ ។

**មាត្រា ៧៤.-**

ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ។

ពន្ធខាងលើនេះរាប់បញ្ចូលនូវពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យនិងពន្ធនៃការជួល ។

ក្នុងករណីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់ឃុំ សង្កាត់ ការប្រមូលចំណូលនេះត្រូវធ្វើក្នុងនាមឃុំ សង្កាត់ ។

ប្រភេទ កំរិតនិងរបៀបរបបនៃការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ខាងលើនេះត្រូវកំណត់ដោយច្បាប់ ។

**មាត្រា ៧៥.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ពីចំណូលរដ្ឋ សំរាប់ថវិការបស់ខ្លួន ។

ធនធានវិភាជន៍នេះរួមមានៈ

- ការផ្ទេរទាំងមូលឬមួយផ្នែកនូវប្រាក់ចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធដ៏ជាក់លាក់របស់រដ្ឋ
- ទាយជ្ជទាននិងធនធានវិភាជន៍ ឧបត្ថម្ភធន ឬអនុប្បទានដែលបានមកពីប្រាក់ចំណូលរដ្ឋ ។

ធនធានវិភាជន៍ខាងលើនេះត្រូវផ្តល់ទៅឱ្យឃុំ សង្កាត់តាមរតនាគារខេត្ត ក្រុង ។

ការរៀបចំនិងនីតិវិធីនៃការផ្ទេរប្រាក់វិភាជន៍ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៦.-**

ឃុំ សង្កាត់នីមួយៗ មានសិទ្ធិទទួលបាននូវប្រាក់កំរៃ ចំពោះការអនុវត្តនូវតួនាទីជាភ្នាក់ងារតំណាងរដ្ឋដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់ឱ្យអនុវត្ត ។

ប្រាក់កំរៃខាងលើនេះគឺជាប្រាក់បន្ថែមពីលើប្រាក់ចំណូលរបស់ឃុំ សង្កាត់ ឬប្រាក់វិភាជន៍ផ្សេងៗដែលឃុំ សង្កាត់ទទួលបានពីប្រាក់ចំណូលរដ្ឋ ។៚.

រាជរដ្ឋាភិបាលឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលត្រូវផ្តល់កំរៃសមស្របដល់ឃុំ សង្កាត់ ដែលបានអនុវត្តតួនាទីជាភ្នាក់ងារតំណាងរដ្ឋដូចបានចែងខាងលើ ។

ក្នុងករណីដែលការប្រគល់អំណាច មុខងាររបស់រដ្ឋមានលក្ខណៈជាអចិន្ត្រៃយ៍ទៅឱ្យឃុំ សង្កាត់រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានធនធានហិរញ្ញវត្ថុរយៈពេលយូរអង្វែងសំរាប់ផ្តល់ឱ្យឃុំ សង្កាត់ ។

ការរៀបចំប្រាក់កំរៃខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៧.-**

រដ្ឋបង្កើតឱ្យមានមូលនិធិឃុំ សង្កាត់ ។

មូលនិធិឃុំ សង្កាត់បង្កើតឡើងក្នុងគោលដៅដើម្បីធ្វើការផ្ទេរនូវប្រាក់ចំណូលពីជាតិនិងប្រាក់ចំណូលផ្សេងៗទៀតទៅឱ្យថវិកាឃុំ សង្កាត់ ។

ការផ្ទេរប្រាក់ចំណូលពីជាតិទៅមូលនិធិខាងលើនេះត្រូវធ្វើឡើងទៅតាមរូបមន្តឬតាមអត្រាជាក់លាក់មួយសំរាប់ថេរៈវេលាយ៉ាងតិច ៣ឆ្នាំ និងមិនលើសពី ៥ឆ្នាំដែលកំណត់ដោយអនុក្រឹត្យ ។

នីតិវិធីអនុវត្តជាក់ស្តែងនៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៨.-**

មូលនិធិឃុំ សង្កាត់បានមកពី :

- ការធ្វើវិភាជន៍នូវចំណែកដ៏ជាក់លាក់នៃប្រាក់ចំណូលរដ្ឋ ពីថវិការដ្ឋប្រចាំឆ្នាំដែលកំណត់ដោយអនុក្រឹត្យ
- អនុប្បទាននិងការខ្ចីពីប្រភពក្នុងប្រទេសនិងក្រៅប្រទេស ។

ការធ្វើវិភាជន៍នូវធនធានប្រចាំឆ្នាំទៅឱ្យឃុំ សង្កាត់តាមមូលនិធិឃុំ សង្កាត់ត្រូវធ្វើឡើងទៅតាមរូបមន្តដែលកំណត់ដោយអនុក្រឹត្យ ។

របៀបរបបចាត់ចែង វិធាននៃការប្រើប្រាស់និងនីតិវិធីនៃការបើកប្រាក់ចំ-ណាយពីមូលនិធិឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៩.-**

ឃុំ សង្កាត់ត្រូវរៀបចំនិងអនុម័តថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ ។ល។



Bu Aw

ថវិកាឃុំ សង្កាត់ត្រូវរៀបចំទៅតាមទំរង់មួយនិងអនុម័តនៅក្នុងកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទមួយអនុលោមទៅតាមប្រពន្ធ័ថវិកាជាតិ ។

ថវិកាឃុំ សង្កាត់ត្រូវមានតុល្យភាពរវាងចំណូលសរុបនិងចំណាយសរុប ។

ឃុំ សង្កាត់អាចបង្កើនចំណាយបាន តែត្រូវឱ្យស្របទៅតាមចំណូលរបស់ខ្លួន ។

ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងអំពីអាទិភាពនិងសេចក្តីត្រូវការនៃផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ ។

នីតិវិធីនៃការរៀបចំនិងការអនុម័តថវិកាខាងលើត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨០.-**

ឃុំ សង្កាត់គ្មានសិទ្ធិខ្ចីប្រាក់បានឡើយ ។

ឃុំ សង្កាត់មិនអាចធានាវ៉ាប់រងចំពោះការខ្ចី ឬកាតព្វកិច្ចហិរញ្ញវត្ថុណាមួយបានឡើយ ។

**មាត្រា ៨១.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវការផ្ទេរទ្រព្យសម្បត្តិមួយផ្នែករបស់រដ្ឋមកជាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ ។

ឃុំ សង្កាត់ត្រូវគ្រប់គ្រងឱ្យបានល្អនូវទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង និងទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យ ។

ឃុំ សង្កាត់អាចប្រើប្រាស់និងទាញយកផលចំណូលពីទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យខ្លួនគ្រប់គ្រង ។

ឃុំ សង្កាត់ត្រូវថែរក្សាការពារទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យៗបានគង់វង្ស ហើយទ្រព្យសម្បត្តិទាំងនោះ ឃុំ សង្កាត់គ្មានសិទ្ធិលក់ដូរឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

នីតិវិធីចាត់ចែងនិងប្រើប្រាស់ទ្រព្យសម្បត្តិខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨២.-**

ឃុំ សង្កាត់ត្រូ[illegible]កឱ្យមាននូវប្រព័ន្ធគ្រប់គ្រង តាមដាននិងត្រួតពិនិត្យហិរញ្ញ-វត្ថុរបស់ខ្លួនដែលរួមមាន : ៧.ត.

- បទដ្ឋានហិរញ្ញវត្ថុនិងការអនុវត្តជាក់ស្តែងផ្នែកគណនេយ្យ

- ការចាត់ចែង គ្រប់គ្រងទ្រព្យសម្បត្តិ

- តំរូវការផ្សេងៗ ក្នុងការធ្វើលទ្ធកម្ម

- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព ប្រសិទ្ធិភាពនិងការទទួលខុសត្រូវ ។

ប្រព័ន្ធនៃការគ្រប់គ្រង ការតាមដាននិងការត្រួតពិនិត្យហិរញ្ញវត្ថុឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨៣.-**

របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាឯកភាពលើគោលការណ៍ជាមួយក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៨៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលវិន័យដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

វិន័យរួមមាន :

- ស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានកំណត់ហេតុច្បាស់លាស់

- ករណីនៅតែបន្តប្រព្រឹត្តកំហុស ត្រូវកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភ ។

វិន័យដែលតម្រូវឱ្យកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភដូចចែងខាងលើអាចអនុវត្តបាន លុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រាក់ឧបត្ថម្ភដែលកាត់នេះត្រូវបានមកជាប្រយោជន៍នៃថវិកាឃុំ សង្កាត់ ។ល។

ក្នុងករណីបានអនុវត្តបភាពវិន័យទាំងពីរខាងលើរួចហើយ តែសាមីខ្លួននៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដោយការបោះឆ្នោតអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ហើយត្រូវធ្វើការជ្រើសរើសសមាជិកថ្មីមកជំនួសតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ទទួលវិន័យ ត្រូវជ្រើសយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឬមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុវត្តបភាពវិន័យខាងលើនេះ ។

មន្ត្រីដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំខាងលើនេះពុំមានសិទ្ធិអនុម័តឡើយ ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៥.-**

ដើម្បីមានមូលដ្ឋានសំរាប់រៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់និងគ្រប់គ្រងឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសអំពីចំនួន ឈ្មោះនិងព្រំប្រទល់របស់ឃុំ សង្កាត់ ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ ។

**មាត្រា ៨៦.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ១ នេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំឡើងវិញនូវមេភូមិនានាចំណុះឃុំ សង្កាត់របស់ខ្លួនទៅតាមបែបបទនីតិវិធីដូចមានចែងក្នុងមាត្រា ៣០នៃច្បាប់នេះ ។

**មាត្រា ៨៧.-**

ដើម្បីបង្កលក្ខណៈសម្បត្តិដល់ការគ្រប់គ្រងឃុំ សង្កាត់តាមប្រព័ន្ធវិមជ្ឈការត្រូវបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយឈ្មោះថា "គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់" ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន ។ល។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតបន្ទាប់ពីច្បាប់នេះបានចូលជាធរមាន ហើយត្រូវបញ្ចប់អាណត្តិរបស់ខ្លួនឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចចែកចេញជាអនុគណៈកម្មការតាមការចាំបាច់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវយកអង្គភាពដែលបានបង្កើតឡើងស្របតាមមាត្រា ៥៩នៃច្បាប់នេះធ្វើជាលេខាធិការដ្ឋាន ។

**មាត្រា ៨៨.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ចធ្វើសេចក្តីស្នើយោបល់ទៅក្រសួងមហាផ្ទៃនិងរាជរដ្ឋាភិបាលអំពីបញ្ហានានាដូចខាងក្រោម :

- សិក្សាស្រាវជ្រាវកំណត់ឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់ទាំងអស់ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បែងចែកមុខងារ សិទ្ធិអំណាចនិងភារកិច្ចផ្សេងៗ រវាងរាជរដ្ឋាភិបាលនិងឃុំ សង្កាត់ព្រមទាំងរៀបចំឱ្យមានកិច្ចសហការសំរបសំរួលរវាងឃុំ សង្កាត់ ពីរឬច្រើន ។
- បណ្តុះបណ្តាល បង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់
- រៀបចំប្រាក់ចំណូលនិងសារពើពន្ធសំរាប់ឃុំ សង្កាត់
- គាំទ្រផ្នែកបច្ចេកទេសដល់ឃុំ សង្កាត់
- វិះរកមធ្យោបាយសំរាប់ផ្តល់ព័ត៌មាននិងគំរង់ទិសរដ្ឋបាលសាធារណៈអំពីកិច្ចដំណើរការនៃប្រព័ន្ធគ្រប់គ្រងឃុំ សង្កាត់តាមបែបប្រជាធិបតេយ្យនិងវិមជ្ឈការ
- ផ្តល់យោបល់ដល់រាជរដ្ឋាភិបាលអំពីការអនុវត្តនយោបាយវិមជ្ឈការក្រោមអំណាចនៃច្បាប់នេះនិងផ្តល់យោបល់លើការកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំព្រាងលិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ
- រួមយោបល់ទៅលើអនុក្រឹត្យដែលមានការពាក់ព័ន្ធដល់ការងារនៅថ្នាក់ឃុំ សង្កាត់ ល។

- កំណត់របបគ្រប់គ្រងរដ្ឋបាលអន្តរកាលចំពោះឃុំ សង្កាត់ដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តនយោបាយវិមជ្ឈការ ។

**មាត្រា ៨៩.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយផ្អែកតាមសេចក្តីស្នើយោបល់របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចស្នើបង្កើតឃុំ សង្កាត់ លុបចោលឃុំ សង្កាត់ កែប្រែព្រំប្រទល់ឃុំ សង្កាត់ ផ្លាស់ប្តូរឈ្មោះឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦ និងមាត្រា ១៨នៃច្បាប់នេះ សំរាប់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ២ ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៩០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។៚

រាជធានីភ្នំពេញថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១

ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ហត្ថលេខា**

ស ខេង យូ ហុកគ្រី

លេខ : ៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ ៣ ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ស៊ុំ ម៉ាន់